# រឿងសុវណ្ណហង្ស

## ទី-២

B-2
D-82
N-2922



រឿ-រឿ
117

1953-2
ថ.2
ARCHIVES NATIONALES
ARCHIVES NATIONALES
CÔTE B-114-1966
82



ព្រាហ្មណ៍ស្តាប់ព្រះបន្ទូល ស្រេចព្រាហ្មណ៍ទូលព្រះបិតា បពិត្រព្រះ
រាជា កុំព្រួយព្រះទ័យឡើយហោង ៗ ខ្ញុំធានាប្រោសប្រស់ ស្តេច
ឲ្យរស់ដូចបំណង កុំបីព្រះច្បះច្បង ព្រួយព្រះទ័យថប់អារម្មណ៍ ៗ
ស្តេចឲ្យរៀបសន្និយា បាំងបិទជាប្រាំពីរជុំ ស្រេចហើយទើបអញខ្ញុំ
ចូលទៅប្រស់ព្រះរាជា ៗ ស្តេចស្តាប់ព្រាហ្មណ៍ក្រាបទូល ក្សត្រឥស្សូរ
ត្រាស់ទៅថា ហៃអស់ទាំងសេនា យកវាំងននបិទបាំងឆាប់ ៗ មន្ត្រី
ផងខ្ជីខ្ជាន់ រៀបបន្ទាន់ដូចបង្គាប់ ស្រេចទើបព្រាហ្មណ៍បញ្ជាប់ យាង
យាសចូលក្នុងសន្និយា ៗ ឲ្យព្រាហ្មណ៍គម្ពលនៅ ចាំទ្វារក្រៅហើយ
ជាយា ចូលដល់យល់ក្សត្រា នាងទល់ទុក្ខពុំបានឡើយ ៗ ព្រាហ្មណ៍
កេតសុរិយង្គណា លើកបាទាក្សត្រត្រាណត្រើយ ដាក់លើសិរសាហើយ
ទួញឱបសពពុំស្រាកឡើយ ៗ គគក់គ្រែះទុក្ខ នាងជាយាសោកពុំ
ស្បើយ ទួញថាម្ចាស់ខ្ញុំអើយ ស្តេចមកក្ស័យនៃជន្មា ៗ គេចាក់ព្រះ
មហាក្សត្រ ត្រូវប្រាកដត្រង់ទុក្ខ សំពែងជាប់នៅទា ទ្រង់ព្រះអង្គដក
ពុំបាន ៗ ខ្ញុំតាមព្រះរាជា ឈាមក្សត្រាស្រក់ដោយដាន តាម
ឈាមក្សត្រប្រធាន លុះដល់ព្រៃធំស្រោងស្រុង ៗ ឈាមពុំឃើញ
ឡើយណា ខ្ញុំយាត្រារកព្រះអង្គ ពុំឃើញឡើយខ្ញុំទ្រង់ កន្សែង
សោកសន្ធប់លង់ ៗ ព្រះឥន្ទស្តេចលេលា យកគង្គាមកស្រោចស្រង់
ខ្ញុំភ្ញាក់ឡើងព្រះអង្គ ព្រះឥន្ទឲ្យថ្នាំឱសថ ៗ ប្រោសប្រស់ព្រះរាជា
ឥឡូវណាឲ្យប្រាកដ នាងលើកបាទមហាក្សត្រ ដាក់ដំកល់លើសិរសា ៗ

បន្ទោះសោកស្រេចស្រស់ ទើបទិមិលវិវន្ទ ហើយយកខុសថា លាប
លំពែងស្រេចស្រីថ្ងៃ ៗ ដកលំពែងរួបស្រេច នាងស្រីរតន៍គន់ពៃ
ពុំមានស្នាមឡើយនៃ នាងត្រេកអរពន់ពេកក្រៃ ៗ ហើយយកខុសថា
លាបអង្គាមហាក្សត្រថ្ងៃ សព្វសុរិលនៃចក្រី ទើបស្តេចភ្ញាក់ព្រះអង្គ ៗ
ស្តេចក្រោកឡើងឆាប់ខ្ញី ព្រះចក្រីទតយល់យង់ នាងព្រាហ្មណ៍រូបបញ្ចង្គ
ហាក់ដូចអង្គនៃផាយា ៗ ចាប់ខ្ញុំរូបរិតនៅ បន្ទូលទៅហៃប្អូនភ្ញា
គាប់ចៃចិត្តស្នេហា ស្ងែងស្ងូះមករកដល់ទី ៗ ហើយស្តែងស្តេចប្រាក់
ចាប់ថនាព្រះប្អូនស្រី ពុំឃើញឡើយចក្រី ស្តេចអន់អៀនព្រះកត្រា ៗ
ហើយខំរៃកស្បៃមើល ឲ្យប្រសើរនឹងនេត្រា ពុំឃើញឡើយស្តេចថា
ឱអញស្មានជាក្សត្រី ៗ រូបអង្គទ្រង់ផាយា ប្រែហែលជាវក្សត្រី កេត
សុរិយង្គប្អូនស្រី ឯណោះនាងយកទៅណា ៗ ស្តេចខឹបៗរងរ៉ែត កៀក
ដួញជិត ៗ ខុក ថើបថៃអស់អង្គា យល់មន្ទិលហើយមហាក្សត្រ ៗ
អន់អៀនខុនទិត្យនៅ ព្រះបមហៅស្តេចស្ងៀមស្ងាត់ ពុំមានព្រះសាសាត់
ចុងព្រះនេត្រទតមួងៗ ៗ ក្សត្រីស្រីព្រាហ្មណា យល់ក្សត្រាពុំសា
សង មានបន្ទូលស្នេហ៍ស្នង ទូលព្រះរៀមព្រះភជា ៗ បពិត្រព្រះ
មហាក្សត្រ ស្តេចស្ងៀមស្ងាត់ពុំបរចា ពីដើមស្តេចមិម្នា ចាប់ខឹប
ថើបថៃអស់ក្តី ៗ រកដោះរកដូនស្រេច គួរសំរេចរួមបេតី ស្នេហ៍ស្និទ្ធ
មិត្រមេត្រី ស្តេចស្ងៀមស្ងាត់ពុំបរចា ៗ ខ្ញុំជាប្រសពេញពិត ស្តេច
ពុំគិតខ្លាសគេណា ខ្ញុំជាព្រាហ្មណ៍ពិទក្រ មកប្រោសប្រស់មហាក្សត្រ

ថ្ងៃ ៗ លោកដែលមានអ្នកណា ប្រុសដូចគ្នាបង់គ្នានៃ ដូចព្រះអង្គ ក្សត្រថ្ងៃ ស្ដេចមកបង់ឯទេព្យា ៗ បពិត្រមហាក្សត្រក្សាន្ត ឥឡូវ បានរស់ហើយណា ខ្ញុំសូមទានក្រាបលា ព្រះអង្គទៅឥឡូវនៃ ៗ សូម ស្ដេចគង់សម្រាន្ត ឲ្យសុខសាន្តព្រះហឫទ័យ ខ្ញុំសូមលាក្សត្រថ្ងៃ ឥឡូវ នឹងចេញបរថ្វាត់ ៗ ព្រះពោធិវង្សល ស្ដាប់បន្ទូលព្រាហ្មណ៍លាក្សត្រ ថាព្រាហ្មណ៍អើយបង់ឃាត់ កុំអាលត្រាច់បរលេលា ៗ បំណាច់អ្នក មានគុណ ប្រែស់ជីពជន្មរស់ហើយណា មកយើងនឹងនាំគ្នា ទៅពន្លាពី ពន្ធ័ក្សត្រ ៗ ជាព្រះវរបិតា ព្រះមាតាឥស្សូរថ្វាក់ ព្រាហ្មណ៍ព្រះ រៀមឃាត់ ខានតាមបទព្រះដៀសជ័យ ៗ

បឧតាកាកតិ

បន្ទូលម្ដោះស្រេច កាលណោះទើបស្ដេច នាំព្រាហ្មណ៍ក្សត្រី បើក ព្រះសន្ទិយា យាត្រាឆាប់ខ្ញី ព្រះបាទចក្រី ស្ដេចដល់ក្រៅថ្វាត់ ៗ អស់មុខមន្ត្រី សេនាបតី រាស្ដ្រផងប្រិនក្ដាត់ អករ់យាយចាស់ទុំ ព្រះ ស្នំចក្រវត្តិ មើលយល់មហាក្សត្រ រស់រួចជីវី ៗ ត្រេកអរឆោឡោ កកើតជាគោ. លាហលពិតពី ប្រាសាទវិមាន ក្សត្រក្សាន្តជាប៉- តា នូវជំនី រត់រួសយាត្រា ៗ ដល់ព្រះរាជបុត្រ ពន្ធកពង្សពុទ្ធ ស្រេច ព្រះមាតា ឱបអង្គស័ក្រស្មោះ បំពោះរាជា រួបរស់ជន្មា ត្រេចអរពេក ក្រៃ ៗ ព្រះវរបិតា ស្ដែងស្ដេចប្រាប់ ឱបអង្គព្រាហ្មណ៍ថ្ងៃ បន្ទូល ស័ក្រស្មោះ បំពោះថាហៃ ចៅព្រាហ្មណ៍មាសថ្ងៃ មានគុណពេកក្ដាត់ ៗ

ឪពុកអើរសល់ ឪពុកបានយល់ ព្រះកេក្តិបុត្ររតន៍ អ្នកព្រាហ្មណ៍
ប្រោសប្រស់ រូបរស់ប្រាកដ ឪពុកសន្ទត ឲ្យពជរង្វាន់ ៗ ឥឡូវ
នេះណា នគរគ្រាមា ទ្រព្យផងណាស់ណាន់ ឪពុកលើកឲ្យ កូន
ស្ងួនសោភ័ណ ដាក់ជារង្វាន់ អ្នកព្រាហ្មណ៍ទេព្យា ៗ ពាង់ស្តាប់
បន្ទូល ព្រះបាទឥស្សូរ ជាតិជាបិតា នាងក្រាបសិរសិត ជួញជិតសិរសា
ហើយនាងទូលថា ខ្ញុំពុំហ៊ានយក ៗ ខ្ញុំជាព្រាហ្មណ៍តែ ប្រស់ក្សត្រ
ជៀសជ័យ ហើយខ្ញុំត្រាប់រក ស្នឹងស្នាធ៌ដោយទី គិរីឈូរឪធក ប្រា
ថ្នាទឹងរក តែបុណ្យផលា ៗ ព្រះបាទឥស្សូរ មានព្រះបន្ទូល សួរ
បុត្រថ្ងៃថា ហែកូនពន្ទក ទន្ទុកបិតា ហេតុម្តេចបានជា គេពាក់មាស
ថ្ងៃ ៗ ព្រះសុវណ្ណហង្ស ស្តាប់ហើយព្រះអង្គ ក៏ថ្វង់សម័យ ថា
គេតសុរិយង្គ ពុំត្រង់ឡើយនៃ ខ្ញុំបួលសព្វថ្ងៃ ពិតពុំសង្កា ៗ លុះ
ថ្ងៃមួយកាល នោះរាត្រកាល រាត្រើយន្តជា លំពែងដាក់បំ កណ្តាលទឹក៉
ត្រូវខ្ញុំលេលា បរបួលស្នានស្មោះ ៗ បួលដល់ទ្វារដាក់ កន្ទ្រះយន្តធាក់
លំពែងដោតត្ពោះ ចាក់បុងជង្ហើម គួរសៀមកាលនោះ សន្ទប់សូន្យ
សោះ ស្មើរក្ស័យជីវី ៗ លុះភ្ញាក់ភ្ញាក់ប្រាណ ស្រែកហៅពុំមាន ឮ
មាត់សំដី រាត្ចូនសម្ងំ សុខុមកង្កទី ខ្ញុំខំបរលើ. លាមកដោយខ្យល់ ៗ
លុះដល់វិមាន ក្សិណក្ស័យកង្កថាន ទិព្វទេពមណ្ឌល ទេវតាមកជួយ
ជួនកូនបានដល់ បិតាបានយល់ ខ្មោចខ្ញុំហើយណា ៗ ម៉្ហ៊ះសមរាអរ
គិតថាខ្ញុំមរណ៍ ជីវិតសោះសា ឥឡូវរូបរស់ ជាមនុស្សខ្ញុំលា ពាន

[illegible]

ទៅភាគ សម្លាប់ឲ្យក្ស័យ ៗ ព្រាហ្មណ៍សុរិយគ្គ ស្ដេចស្ដាប់ព្រះអគ្គ ទូលស្រេចហើយនៃ នាងព្រាហ្មណ៍ទូលឆ្លើយ ម្ចាស់អើយកុំធ្វើ ហួន បាបក្រាស់ក្រៃ ហាក់មុសាពន់ ៗ លោកដែលឯណា ជាតិជាភរិយា សម្លាញ់សល់ខ្នាត សម្លាប់ស្វាមី ក្ស័យជីពជាតិ កុំអាលព្រះបាទ ខ្វល់ទឹងនាងណា ៗ ក្រែងអ្នកដទៃ សម្លាប់ក្សត្រថ្វៃ ហើយព្រះភូបាល ខ្វល់ទឹងមហេសី ក្សត្រីពេញពាល យល់ខុសធម្មតា បានបាបក្រាស់ ក្រៃ ៗ ស្ដេចស្ដាប់ព្រាហ្មណ៍ប្រាជ្ញ ធ្លាស់ឆ្លើយឥតខ្លាច ទើបព្រះចោម ក្រៃ តតបទៅថា ស្ងួនភ្ងាឯងនៃ មិនអ្នកដទៃ ទេព្រះបិតា ៗ ឈ្មោះ គេតសុរិយគ្គ រូបកង់ព្រាយព្រង ខ្ញុំចាំក្ដាត់ណា ចូរនាងបែកបាយ និយាយបរចា ប្រាប់បងឆាប់ក៏ សោះបងសង្ស័យ ៗ បើអ្នកឯទៀត ពុំហ៊ានធ្វើយទៀត ទាស់ទែងឡើយនៃ គេតសូរិយគ្គអើយ កុំធ្វើយ ពន់វៃ ប្រាប់បងណាស្រី ឲ្យឆាប់កុំផ្សង ៗ ទៅព្រាហ្មណ៍ស្ដែងស្ដាប់ ព្រះរាជសារសព្ទ ក្សត្រីទន្ទឹង បែរព្រះភក្ត្រថ្វៃ ចេញខ្ញុំដោះត្រង់ កម្ពុលយក្សយង់ ញឹមៗគាន់គ្នា ៗ ព្រះសុវណ្ណហង្ស បែរបៀតព្រះ អគ្គ ចូលជិតជីតា ឧទឧបរួបរិត ដួញជិតឱប ក្សត្រីកញ្ញា បម្រេះ រួបបេញ ៗ ស្ដេចត្រាស់ទៅថា ហៃនាងជាយា ស្រស់ស្រីភាល ពេញ ប្អូនជាមហេសី ប្រិមប្រិយសម្លាញ់ ចូរនាងស្លុះចេញ ពីបង ណាពៅ ៗ នាងស្ដាប់ព្រះសូរ ក្សត្រីរន្ធួល បន្ទូលទៅពៅ បពិត្រ ព្រះបាទ នរនាថចមចៅ ស្ដេចចាប់ខ្ញុំនៅ មុខព្រះបិតា ខ្ញុំខ្ញាស់

គេដល់ ម្តេចព្រះទសពល ចាប់ឱបខ្ញុំជា ព្រាហ្មណ៍ប្រាជ្ញប្រាស
ប្រស់ ជាប្រុសដូចគ្នា មានដោះត្រង់ណា ស្តេចថាខ្ញុំស្រី ។ មុន
មិញចាប់ខ្ញុំ ស្ទាបដោះដូចតុំ ឃើញឡើយក្សត្រថ្ងៃ ឥឡូវស្ទាបទៀត
ចំផ្ទៀតរំពៃ រកដោះទៀតនៃ ដោះមានត្រង់ណា ។ គួរខ្មាស
មហាក្សត្រ មន្ត្រីច្រើនក្តាត់ វង្គពស្ត្រប្រជា ពាសពេញណាស់ណាន់
គាប់គាន់គ្រៀបគ្រា គួរណាស់ដេផ្លា ម្តេចស្តេចស្នេហ៍ស្នធ ។ ព្រះ
ពោធិសត្វ ខ្មាសព្រាហ្មណ៍ពេកក្តាត់ ពិតពុំសាសង ក្រាបថ្វាយបង្គំ
ប្រណមព្រ៉ប់រង នាំព្រាហ្មណ៍ចូលផ្គង ប្រាង្គប្រាសាទរ័តន៍ ។ ដល់
ហើយព្រះអង្គ ព្រះសុវណ្ណហង្ស បន្ទូលសាសាប់ ហៃអាមាត្យអើយ
លីលាឆាប់ថ្វាត់ ទៅរៀបពជរថ ឥឡូវឆាប់វៃ ។ ទៅប្រាប់សេនា
កំណាន់អាសា អាមាត្យមន្ត្រី ដ្បិតអញលីលា យាត្រាលេងព្រៃ
ឲ្យឆាប់ៗវៃ ឥឡូវនេះណា ។ អាមាត្យស្តែងស្តាប់ ទទួលបង្គាប់
បង្គំក្រាបលា ប្រាមប្រាប់សេនីយ មន្ត្រីសេនា រៀបពជរថា ពល
ពាលកំណាន់ ។ ស្រេចចូលវន្ទា ព្រះបាទក្សត្រា នាំព្រាហ្មណ៍
រួសរាន់ ស្រង់ព្រះគង្គា គន្ធាខ្មីខ្មាន់ ទ្រង់គ្រឿងសោភ័ណ មកុដកែវ
សូរ្យកាន្ត ។ ទ្រង់ព្រះពស្ត្រមាស រុងរឿងឧភាស ប្រពៃមនមាន
សង្ហាកន្ទន់ ចិត្តគន់រូបហាន ហាក់ទេពចាកឋាន ត្រៃត្រឹង្សសួគ៌ា ។
ស្រេចស្តេចចេញចរ នាំព្រាហ្មណ៍បវរ ឡើងគង់រថា ព្រាហ្មណ៍
ជិះកន្ទៀ ក្សត្រថ្ងៃនាំណា ចេញចាកប្រាង្គប្រា- សាទសួគ៌បវរ ។

## បទកុជង្គលីលា

រាជរថបរិសុទ្ធក្បួរ រៀបទឹមអស្សតរ ចេញតាមភាគ ៗ ពលេ
ផងអឹងកងគ្រៀបគ្រា ហែព្រះរាជា ច្រើនក្រៃពេកពន់ ៗ ក្លស់ខ្ចី
អភិរម្យចេញមុន ហែក្សត្រមានបុណ្យ បើកបាំងគ្រៀបគ្រា ៗ ស្គរទូង
ស្គរទ័ពស្គរជ័យ ស្គរចិនស្គរជា ច្រើនពន់ពេកក្រៃ ៗ លុះដល់
មណ្ឌលព្រឹក្សព្រៃ សួនកែវហើយនៃ បុះពីរថា ៗ ស្តេចនាំទៅ
ព្រាហ្មណ៍លីលា ទតអស់បុប្ផា ក្រសាលសប្បាយ ៗ បេះផ្កា
ចម្ប៉ីកែកាយ រាក់រួតពណ្ណរាយ គារកេះកីគា ៗ ស្រឡីតដុះជិតក្តាំងផ្កា
ចម្បីចម្បា ម្ទេះរួចម្ទេះរាយ ៗ រំដេញរំដួលគ្រសាយ គ្រសុំកែកាយ
រីកពេយកែសរ ៗ កន្ទន់ទ្រហឹងខ្លាយខ្នុរ ក្រេបត្រឹបកែសរ សត្វ
ដោយព្រឹក្សា ៗ ស្តេចបេះប្រលេះបុប្ផា ហុចឲ្យព្រាហ្មណា ទទួលកាន់
នៅ ៗ ដឹងហេតុកិនភេទព្រះទៅ លម្រង់ចិត្តបោះក្បួ គិតគួរឆ្លើយស្នង ៗ
បពិត្រមហាក្សត្របព្វស់ប្យង ៗ ខ្ញុំព្រាហ្មណ៍នេះហោង ពុំសូវចេតនា ៗ
នឹងបេះប្រលេះបុប្ផា ធ្វើអ្វីក្សត្រា ខ្ញុំពុំសាទរ ៗ ស្តេចស្តាប់សាសព្ទ
គួរ យល់ព្រាហ្មណ៍ពុំអរ ព្រួយព្រះហឫទ័យ ៗ ធ្វើកិច្ចកលម្តេច
ធ្នេះនៃ ឲ្យដឹងជាប្រិយ សោះមានសង្កា ៗ គួរអញនាំចេញយាត្រា
ទៅលេងនៅនា គុហាមាសមៃ ៗ មើលអស់ត្បូងផងច្រើនក្រៃ ទើប
ដឹងថាស្រីឥឡូវនេះណា ៗ គិតស្រេចស្តេចនាំលីលា ដើរដល់
គុហា កែវកែមប្រពៃ ៗ ទតអស់ត្បូងផងច្រើនក្រៃ សូរ្យកាន្តទិព្វថ្ងៃ

បទុមកយរ័តន៍ ៗ មុក្តាមហាមកិត និលនៃបុស្សរ័តន៍ ពិទូរ្យពិទាយ ៗ

ពពាលរ័តន៍កយពណ្ណរាយ ទទឹមឆើតឆាយ គ្រប់ពណ៌នានា ៗ នាង

ដឹងដំណឹងក្សត្រា ល្បងចិត្តជាយា ទើបវរក្សត្រី ៗ ទតយល់កម្ពល

អសុរី ចរចង់រើសមណី ទើបវរជាយា ៗ ឈប់យកសុពណ៌ បាទា

កម្ពលព្រាហ្មណា ដឹងដើមក្សត្រិ ៗ ហុចស្បែកបដើងឆាប់ខ្ញី នាងខ្សឹប

ស្រដី ហៃបងកម្ពល ៗ ស្តេចល្បងចិត្តយើងអស់កល បើបងយល់

យល់ កុំរើសយកឡើយ ៗ នាងពាក់ស្បែកជើងរួចហើយ ក្សត្រី

ត្រាណត្រើយ យាត្រាតាមក្សត្រ ៗ យកមណីរ័តន៍ពេយប្រាក់

ខៀវលឿងប្រិនក្លាត់ ខ្មៅសចៃតង ៗ ដោយពណ៌ល្អសល់កន្ទង

ព្រះទ័យនាងហោង ចង់ចាប់ស្នេហា ៗ ក្សត្រីប្រិមប្រិយសោភា

នាងនាថធ្វើជា ស្ងៀមស្ងាត់ព្រងើយ ៗ ស្តេចយល់អស់កលហ្នោះ

ហើយ ក្សត្រាត្រាណត្រើយ ព្រួយព្រះទ័យា ៗ គួរអញនាំចេញ

ទៅនា ទីស្រះគង្គា ទឹកថ្លាយល់យង់ ៗ បើជាតិជាស្រីបុះក្នុង ទឹក

នោះហើយអង្គ ប្រាណប្រែកាយា ៗ ឈាមចេញពីព្រះអង្គា ទើប

អញដឹងជា ក្សត្រិកល្បាណា ៗ គិតស្រេចស្តេចស្តេចចុះឋាន ក្នុង

ស្រះមៃទមាន ហើយហៅព្រាហ្មណា ៗ ក្សិណព្រាហ្មណ៍ដ៏កល

ក្សត្រា ពិតពុលីលា ទើបវរក្សត្រី ខ្សឹបខ្សៀវនឹងព្រាហ្មណ៍ថាហៃ

បើមយាក្សថ្ងៃ ខំផ្សុបុះផ្គង ៗ បងប្រែក្រឡាប្រូវង ជាមាន់មួយ

ហោង ប្រោះឲ្យខ្ញុំថ្លុត ៗ កម្ពលស្តាប់ហើយប្រយ័ត្ន ចាំពាក្យសា-

សាត់ សៀមស្វាត់ពាធា ។ ព្រះបាទនរនាថថ្លៃថ្លា ពុំដឹងមាយា
ក្សត្រីវរវង្ស ។ ស្ដេចហៅទៅពីក្នុង ស្រះហើយព្រះអង្គ បន្ទូល
ត្រាស់ថា ។ ព្រាហ្មណ៍អើយចុះមករួសរ៉ា ធ្វើអ្វីវេរា ពិតពុំចង់
ចុះ ។ ក្សត្រីប្រិមប្រិយព្រោះ ពុំដឹងបើដោះ សាសង់ពាធា ។
នាងនាថត្រអាលម្ចីម្ចា ចរចុះគង្គា តាមព្រះចក្រី ។ ចុះទាំងយក្សាអសុរី
ដល់ក្នុងជលធី នាងនាថអស្ចារ្យ ។ មេលទឹកពន្ទឹកពិភាល់ ក្សត្រី
នាងស្គាល់ មិចព្រះនេត្រា ។ ក្សិណាក្រុងកម្ពុលអសុរា និម្មិតក្រឡា
ជាកូនមាន់នៃ ។ បង្ហើរដួចដល់ក្សត្រី នាងចាប់មាន់ឈ្មី នឹងព្រះ
ឱភា ។ រីទឹកពន្ទឹកមហិមា ដល់នាងធីតា ចរចុះចូលក្នុង ។ ចេញ
ឈាមរហាមពីអង្គ ក្សិណាក្សត្រវរវង្ស ទតព្រះនេត្រា ។ យល់
ឈាមៈចេញពីអង្គា ស្ដេចអត្រាស់ថា ហៃមេមាសថ្លៃ នាងឯង
ជាតិជាមហេសី ទេពីប្រពៃ ពិតពុំសង្កា ។ ឈ្មោះកេតសុរិយង្គ
ហើយណា កុំនាងធីតា លាក់នឹងបង់ឡើយ ។ នាងស្ដាប់សាសព្ទ
ជាក់ហើយ ក្សត្រីត្រាណត្រើយ ឆ្លើយទូលវិញថា ។ ខ្ញុំជាប្រុស
ទេក្សត្រា កុំព្រះពជា បន្ទូលដូច្នោះ ។ ឃើញមាន់ឈាមហៀរស្មោន
ស្មោះ ឈាមមាន់ពាចុះ មកតីឯណា ។ ហើរដល់ដល់នូវឱភា ខះ
ឈ្មីសោះសា ឈាមពាច្រើនក្រៃ ។ បើស្ដេចពុំជឿឡើយនៃ ខ្មោច
មាន់ចង្រៃ នៅលើឱភា ស្ដេចទតយល់ខ្មោចមាន់ជា បន្ទាល់នៅ
នា ខាងខ្លួនក្សត្រី ។ ស្ដេចថាឱកម្មពៀរអ្វី មាន់ខ្ចូចក្ស័យមី ហើរ

មកពីណា ។ ឲ្យតែអញម្នេញចិន្តា ខ្មាស់ព្រាហ្មណ៍ព្រឹទ្ធា ឡើយ ពីស្រែះស្រី ។ ស្ដេចនាំទៅព្រាហ្មណ៍ឡើងខ្មី ព្រះបាទបក្រី ស្អូលអន់ទុក ។ គង់នៅប្រែប្រួលវេលា ចូលក្នុងនគរ ដល់ប្រាសាទ ឋាន ។

## បទកាកគតិ

ព្រះសុវណ្ណហង្ស អម្បូរតូចតង្ស នាំព្រាហ្មណ៍ចូលឋាន ក្រឡាបន្ទំ បរមសុខសាន្ត បន្ទូលស្មោះស្មាន ស្មោះស័គ្រចិន្តា ។ ហៃព្រាហ្មណ៍ ប្រិមប្រិយ មុខមាត់ស្រស់ស្រី គឺអង្គការិយា នាងផុំសម្រាន្ត កំសាន្ត អង្គា បងថ្នមបួនក្លា ឲ្យអស់ព្រះទ័យ ។ ទុកគេតសុរិយង្គ បង ភ្ញាប់យល់អង្គ មេមាសមួលមៃ ត្រើត្រេកចិន្តា ស្ងួនក្លាសព្វថ្ងៃ កម្ម ពេញឲ្យវៃ ឲ្យឃ្លាតបង់បាត់ ។ កាលណាទឹងបាន ឃើញមុខ មាសមាន មេត្រីប្រតិព័ទ្ធ បងថ្នមស្ងួនថ្ងៃ ប្រពៃរូបរ័តន៍ តាំងអង្គ មាសបាត់ ព្រោះបងឃ្លាតឃ្លា ។ ស្ដេចបីដាក់ដល់ ទុកទសពល សែនសោយសោកា ធេរធោងព្រះអង្គ លន់លង់ទយា ដាក់ព្រាហ្មណ៍ ពេទ្យា កើយខ្នើយជាមួយ ។ ព្រាហ្មណ៍កេតសុរិយង្គ អាសូរព្រះ អង្គ ហាក់ទឹងល្ហួយ ពង់ពោះខ្លាចផ្សា ទយាបង់ឲ្យ ស្ដេចប្រាថ ដើមដោយ អាថិអត្ថិតា ។ គឺមោះនាងខ្លាច ក្រែងស្ដេចពុំអាច អត់ទិនទោសា ផ្សិតអញពុំប្រាប់ សាសព្វវាចា សមក្សត្រត្រាណា ខ្វាល់ទឹងអញនៃ ។ នាងផងការណ៍ស្រេច កាលនោះសម្ដេច រ័ត្ន

រាជទេពី ស្ងៀមស្ងាត់សាសង ផ្ទុំផងបក្រី យល់យប់ហើយនៃ រ័តន៍
រាជជាយា ៗ យល់ស្តេចផ្ទុំស្កល់ នាងនាថនិមិល ក្រោកឡើងមីម្មា
សរសេរសំបុត្រ បរិសុទ្ធសោភា សាសព្ទអក្ខរា ទុកថ្វាយក្សត្រថ្ងៃ ៗ
សន្ធតអក្សរ នាមនាងបវរ កេតសុយគ្គនៃ ក្រាបទូលព្រះបាទ នរនាថ
ជៀស្ឋជ័យ ឲ្យជ្រាបសេចក្តី ពីអត្ថិតា ៗ ដ្បិតកិលៀងប្រាំ រាំគិត
ឃ្មាំចាំ ចាក់ព្រះរាជា ខ្ញុំពុំដឹងដែរ ជាគេនិន្ទា លុះព្រឹកសុរិយា រៀង
រះបូព៌ា ៗ ខ្ញុំចេញមកក្រៅ ឃើញឈាមព្រះចៅ ពាសពេញនាទ្វារ
ខ្ញុំសោកព្រះអង្គ លន្ទង់អង្គា លុះយប់មីម្មា រត់ពីបិតា ៗ តាមតែ
ស្នាមឈាម ស្រក់ស្រោចរហាម ក្នុងព្រៃព្រឹក្សា បាត់ឈាមពុំ
យល់ ខ្វាយខ្វល់រក ទួញទល់ទុក្ខា សន្ធប់លុះលង់ ៗ រំជួលក្តៅ
ដល់ ព្រះឥន្ទទេសពល វៃស្តង់ស្តេចគូរគង់ ពុំសុខក្សេមក្សាន្ត ចុះ
ប្តានត្រាប់ត្រង់ ប្រោសប្រស់ខ្ញុំគង់ ជីវិតជន្ទា ៗ សម្តេចកោសី ស្តេច
ប្រស់ខ្ញុំនៃ ជាព្រាហ្មណ៍ហើយណា ស្តេចឲ្យឱសថ ប្រាកដថ្ងៃថ្វា
ប្រោសប្រស់ក្សត្រា រួបរស់ជីវី ៗ ឥឡូវនេះនៃ សូមលាក្សត្រថ្ងៃ ចេញ
ទៅហើយណា ឧតនោយនៃ បវរថ្វថ្វា សូមព្រះករុណា ស្តេចគង់ក្សេម
ក្សាន្ត ៗ សរសេរស្រេចហើយ ក្សត្រីត្រាណត្រើយ សោយសោកប្រាស
ប្រាណ ទួញទូលព្រះបាទ នរនាថប្រធាន លើកព្រះបាទបាន ដាក់លើ
សិរសា ៗ នាងទតព្រះអង្គ ហ្ឫទ័យសូន្យស្ងុង ញ័រអស់អង្គាស្រេចហើយ
ក្សត្រី ប្រិមប្រីសោភា ទើបនាងលីលា ចេញពីរាជឋាន ៗ កម្តួលយក្ស

យន់ ដឹងដើមព្រាហ្មណ៍ពង្ស យាត្រាដោយដាន ដល់ដើមព្រះវៃជ្រ ស្រីថ្ងៃគលក្ខណា លើកករប្រណិធាន បង្គំទេព ៗ បពិត្រព្រះឥន្ទ្រ ទ្រាទ្រើសទេវិន្ទ្រ សោឡសសួគ៌ា ស្តេចមានព្រះគុណ អនន្តថ្លៃថ្លា ខ្ញុំបានលីលា ទៅដល់ស្វាមី ៗ ទើបខ្ញុំប្រោសប្រស់ ព្រះអង្គបានរស់ រូបរួបជីវ ហើយខ្ញុំវិលឡប់ ក្រឡាប់វិញខ្ចី បានរាជបុរី ឥឡូវនេះថ្វាត់ ៗ ខ្ញុំសូមគេសា ដោះខ្ញុំនោះណា ឲ្យបរិបូណ៌ក្តាត់ ជាតិជាក្សត្រី ប្រិមប្រិយពិចិត្រ សូមព្រះឥន្ទ្រជិត ដៀងជួយទុក្ខា ៗ ផ្សងស្រេចទេវី ប្រែប្រាណជាស្រី ដូចដោយចិន្តា កេសីសោភ័ណ សុជនសោភណា សម្តេចជាយា ហាក់ទេពចុះបរ ៗ រីកម្ពលយក្ស យន់យល់ភ្ញាក់ភ្ញាក់ ដឹងដើមបវរ ចោមចៅក្សត្រី ប្រិមប្រិយល្អះល្អ សុភាពកេសរ វន្ទធីតា ៗ នាងនាថក្សត្រី បន្ទូលថាហៃ កម្ពលយក្សា ចូលប្រែប្រាណកាយ ទ្រង់ទ្រាយឆាយា យក្សអសុរា កុំផ្សងលង់ឡើយ ៗ ក្សិណព្រាហ្មណ៍កម្ពល ប្រែប្រាណដូចគល ដើមដែលវិញហើយ ទើបយក្សក្រញ្ញក្រាប ស្រពាបទូលឆ្លើយ ម្ចាស់ថ្លៃខ្ញុំអើយ ក្សត្រនឹងយាត្រា ៗ ស្រេចទើបទេវី ទៅរាជបុរី ខ្ញុំជូនទៅក៏ កុំព្រួយព្រះទ័យឡើយនៃជាយា នាងស្តាប់យក្សា អរក្រៃគន្លង ៗ បន្ទូលថាហៃ កម្ពលអសុរី យើងលីលាផ្គង រត្នរាជសេមា កាលគ្រានេះហោង ឲ្យដល់ដូចប៉ង ចូលក្នុងនគរ ៗ គិតស្រេចហើយណា នាងនាថធីតា ត្រាប់ព្រៃពនេចរ កម្ពលអសុរី ឃ្មាតខ្ចីហោហា ក្សត្រីបវរ ដូចដល់សេមា ៗ

ស្រេចទើបទេវី បន្ទូលវិញ ហៃកម្ពលបា វិលទៅព្រឹក្សព្រៃ អាស្រ័យ សាលា អរគុណណាស់ណា ទើបឯងអសុរ ៗ ជូនដល់បុរី ទើប ចូលគាល់ទី មណ្ឌលបវរ ក្រែងខ្លាចគេដឹង ដំណឹងកើរ បូរបង បេញចរ ទៀងទៅគុហា ៗ កម្ពលអសុរី ស្តាប់រាជសុវណ្ណី បង្គំ ទូលថា បពិត្រក្សត្រី ប្រិមប្រិយសោភា ក្រជាម្តេចម្តា សូម ទឹកដល់ខ្ញុំ ៗ ខ្ញុំមកឆាប់ថ្ងាត់ ដូចជោយសាសាត់ ព្រះទ័យ ពិតពុំ ខានខាតបន្ទូល ឲ្យយូរឡើយសម អម្ចាស់ឧត្តម ទ្រង់ ព្រះមេត្តា ៗ យក្សទូលក្សត្រី ស្រេចហើយអសុរី បង្គំក្រាបលា ហៀរហោះអណ្តែត ត្រសែតវេហាស៍ ស្រេចដល់សាលា ដូចដោយ បំណង ៗ លុះព្រះសុរិយា ព្រលប់ហើយណា ក្សត្រីទន្ទង នាង បរលីលា យាត្រាញើងញើង ចូលប្រាសាទគង់ ដល់ដូចប្រាថ្នា ៗ ឯស្រីព្រះស្នំ បម្រើពិតពុំ ដឹងដើមជាយា នាងនាថបរគាត់ តាមក្សត្រ ឡើយណា ហាក់ដូចជិតា និត្យនៅសព្វថ្ងៃ ៗ

បទព្រហ្មគីតិ

ទឹងថ្ងៃដែងបរតា ទីក្សត្រាផ្ទំនៅនៃ លុះតើនឡើងជៀស ជ័យ ស្អាបរកនាងព្រាហ្មណ៍ពុំយល់ ៗ ស្តេចរកសព្វដោយ ល្វែង ទីកន្ទ្វែងនាងនិមិល ពុំឃើញស្តេចមកដល់ ទីមណ្ឌល ទើបក្សត្រា ៗ ទតយល់អក្សរនៅ ទើបព្រះចៅចាប់អក្ខរា ទត សាយសព្វហើយណា ស្តេចដឹងដើមជាក្សត្រី ៗ ប្រែប្រាណជា

ព្រាហ្មណ៍មិញ ត្រាច់ចេញមកដល់ទី ស្តេចក្រេវក្រោធសែនទ្វី អស្ចារ្យ
ក្រៃពេកក្តាត់ណា ៗ ឲ្យចាក់ឲ្យក្សិណក្ស័យ ហើយវាក់យតាម
ម្ចីម្ចា មកព្រោសប្រែស់ផន្ទា រូបវាវត់បរចេញខ្ទី ៗ គ្លួរអញតាមវាទៅ
ដល់លំនៅវានោះវិទ សម្លាប់ឲ្យក្សិណក្ស័យ ជីវិតវាឥឡូវណា ៗ
គិតស្រេចទើបព្រះបាទ ស្តេចនរនាថបរយោត្រា ឡើងគាល់ព្រះបីតា
ទូលលាចេញតាមមហេសី ៗ នឹងសម្លាប់ផន្ទា ឥឡូវណាពុំប្រណី
ដំរិតបិត្តទ្រឹស្តិតិរិយ វាបញ្ចោតបំពោតខ្ញុំ ៗ ខ្ញុំស្គាល់ជាក់ហើយណារ
ប្រែកែកថាខ្លួនវាពុំ ជាស្រីឡើយឲ្យខ្ញុំ ខ្ញាស់វាពន់ពេកណាស់ក្តាត់ ៗ
សម្តេចព្រះបីតា ស្តាប់បុត្រាហើយលោមឃៈត់ ថាហៃបាបុត្ររតន៍ កុំ
សម្លាប់គេឡើយណា ៗ គេមានគុណនឹងខ្លួន បើគុំគួនមាសពុំងាំ
ក្សិណក្ស័យនៃផន្ទា ពុំរូបរស់រូបជីវី ៗ ក្សិណព្រះសុវណ្ណហង្ស លុត
ដង្គង់វវទ្ទឹ ក្រាបលាព្រះភូមី លីលាដល់ប្រាង្គប្រាសាទ ៗ ទ្រង់គ្រឿង
គ្រប់បញ្ចគ្គ ព្រះពស្ត្រទ្រង់ទ្រាយល្អស្អាត ស្តេចលីលាសែនទាជ ឡើងគង់
លើរាជអស្សពាហ៍ ៗ ហៀវហោះហាត្រសែត ខ្ពស់អណ្តែតលើវេហាស៍
ស្រេចដល់នគរ ស្តេចសម្រាន្តចាំរាត្រី ៗ នឹងថ្ងៃងៃចងបរបា ពីជាយា
រ័តន៍ប្រិមប្រិយ កាលនាងដល់បូរី គិតរពឹងរងទយា ៗ រីព្រះបាទ
មហាក្សត្រ ខ្វាល់ពេកក្តាត់នឹងអញណា សមព្រះមហាក្សត្រា ស្តេចលី
លាមកឆាប់ថ្វាត់ ៗ បើទោះគួរអញចង់ គិតកុំលង់ឡើយប្រយ័ត្ន ផ្ទើរូប
មាសល្អក្តាត់ ស្រេចហើយផ្តេកលើបន្ទំ ៗ ស្តេចបវចូលមកដល់ ស្តេច

យន់យល់ហើយពិតពុំ– លន់ឡើយព្រះឧត្តមពិឃាតក្ស័យនៃរូបា ៗ
គិតហើយនាងស្រស់ស្រី ប្រើសៅដៃចេញមុម្មា ហៅជាងទង់រួសក៏
ឲ្យមកឆាប់ដូចបំណង ៗ សៅដៃស្តាប់បន្ទូល ពុំលង់យូរឡើយរួសរង់ បង្គំ
លាចុះផ្គង ទៅដល់ផ្ទះជាងឆៀងឆាប់ ៗ ស្រែកហៅទៅជាងថា ចូរ
លីលាចេញប្រញាប់ យកអស់គ្រឿងប្រដាប់ ចរចូលគាល់នាងកញ្ញា ៗ
ជាងស្តាប់ហើយរួសរាន់ រត់ទាន់ដល់ធីតា ទើបនាងបន្ទូលថា ចូរ
ជាងធ្វើរូបអញនៃ ៗ នាងយកមាសមួយពាន់ ជាងរួសរាន់ធ្វើវៃ ៗ ជា
រូបនាងស្រីថ្លៃ សុទ្ធសាធគ្រែពុំឃ្លាតឃ្លា ៗ ចូលថ្វាយនាងស្រីរ័តន៍
ត្រេកអរក្តាត់ហើយជាយា យកទឹកឃ្មុំមកណា នាងចាក់ក្នុងរូបមាស
មៃ ៗ លុះជួបចូលសន្ធិយា នាងធីតាស្រីរ័តន៍ថ្លៃ យករូបមាសប្រ
ពៃ ផ្ដេកលើគ្រែស្របហើយណា៖ ៗ យកព្រះពស្ត្រមាសមៃ ដណ្ដប់
នៃរូបសោភា ក្សត្រីស្រីកញ្ញា នាងយាត្រាឆ្ងាយចាំនៅ ៗ រីព្រះ
សុវណ្ណហង្ស ជាតិពង្សពុទ្ធចមពៅ លុះរាត្រីយប់ជ្រៅ ស្ដេចចរចូល
ក្នុងប្រាសាទ ៗ ទៀនយាមភ្លឺសន្ធា ទើបពង្សពោធិសីហនាទ ទត
យល់រូបល្អស្អាត ទទូព្រះពស្ត្រផ្ទុំនៅ ៗ ស្មានថានាងធីតា ផ្ទុំនិទ្រា
ទើបចមពៅ ហូតព្រះខ័នសំដៅ កាត់ករូបដាច់ខ្ចាត់ខ្ចាយ ៗ

## បទកាកគតិ

ព្រះពោធិសត្វ ខ្វល់ណាស់ពេកក្តាក់ ញាប់ញ័រអង្គកាយ កាប់
រូបសុវណ្ណ សោក័ណពណ្ណរាយ ធ្លាយទឹកឃ្មុំខ្ចាយ ពីរូបថ្លៃថ្លា ៗ

ព្រះពង្សពោធិ៍ ខ្វល់ណាស់ឥតបី ឥតបើឧបមា យកព្រះហស្តថ្ងៃ
ប្រពៃសោភា ក្បន់ឈាមម្មា ហុតហើយក្បត្រថ្ងៃ ។ ស្ថានជា
ឈាមនាង សោយស្រេចត្រាស់ក្បាម ឧអស្វារព្រែក ឈាមផ្អែម
បរិសុទ្ធ ប្រាកដស្រីថ្ងៃ បិត្តត្រង់ប្រពៃ ស្មោះស្ម័គ្រទីងបង ។ កេត
សុរិយេន្ទ្រអើយ កម្ពនាងឯងហើយ ក្បិណក្ស័យនេះម្តង បងខឹងទឹងស្រី
ប្រិមប្រិយទន្ទីន នាងបញ្ចោតបង លួចរត់យាត្រា ។ បើបងដឹង
ជាក់ ជាឈាមវរលក្សណ៍ ផ្អែមល្ហែមពិសា ពិតពុំពិឃាត ជីពជាតិ
ផន្ទា ហេតុបាបបុណ្យ ឯងឲ្យប្រាស់ព្រាត់ ។ ស្តេចសោយសោក
ស្រី សើរក្ស័យជីវី ជីវិតបង់បាត់ ទ្រង់ព្រះកន្សែង ជូនថ្ងៃងពេក
ក្តាត់ ញ័រថ្មើមប្រមាត់ ទៀងទូញទៀតថា ។ នុមេមាសស្និទ្ធ សម
បិត្តវរមិត្ត ទៀងត្រង់ពិតណា ឥឡូវបង់បាត់ ជីវិតមរណា បងស្លាប់
ផងគ្នា មូលមួយស្រីថ្ងៃ ។ បន្ទូលម្ល៉ោះស្រេច ក្បិណនោះទើប
ស្តេច ហូតព្រះខ័នជ័យ អាព្រះសុរង បំណងឲ្យក្ស័យ ក្បិណនាង
ស្រីថ្ងៃ ស្ទុះមកម្ម៉ា ។ ចាប់ព្រះខ័នស្រេច កាលនោះទើបស្តេច
ទតយល់ជាយា ចូលចាប់ព្រះខ័ន រួសរាន់ម្ម៉ា ព្រះបាទក្បត្រា អរ
ក្រៃកន្ទង់ ។ ឧបអង្គប្អូនរ័តន៍ ខ្សឹកខ្សួលពេកក្តាត់ បន្ទូលសាសង
បងស្ថានប្អូនស្រី ក្បិណក្ស័យហើយហោង បងនឹងស្លាប់ផង ណាប្អូន
ពុំង៉ា ។ នាងទូលព្រះបាទ ព្រះបង់នរនាថ ឥស្សូរសិរសា បពិត្រ
ក្បត្រថ្ងៃ ប្រពៃសោភា ខ្ញុំខ្ញុំយល់ជា ខុសនឹងព្រះបង ។ ខ្ញុំធ្វើ

រូបមាស រុងរឿងឱភាស ដូចខ្លួនខ្ញុំហោង ផ្ដេកផ្ដិតសយនា ក្សត្រា ប្បះប្បង ខ្វល់ក្រៃកន្លង ពិឃាតរូបា ។ កំលៀងទាំងប្រាំ រាគិត ឃុំចាំ ចាក់ព្រះរាជា ខ្ញុំពុំដឹងដែរ ជាគេផ្ដន្ទា ខ្ញុំបរលីលា ត្រាច់ តាមព្រះបង ។ ប្រោសប្រែសស្ដេចមាន ព្រះជន្មឡើងបាន ក្នុងចិត្ត ខ្ញុំបង់ ក្រាបទូលព្រះបាទ នរនាថតាមត្រង់ ក្រែងក្សត្រវរវង្ស ពិត ពុំមេត្តា ។ ឥឡូវនេះនៃ សូមព្រះចក្រី អត់ឱនទោសា ខ្លួនខ្ញុំខុស ពិត គំនិតកាលគ្រា នេះសូមករុណា ជាខ្ញុំបាទបង ។ ស្ដេច ស្ដាប់មហេសី ព្រះបាទចក្រី បន្ទូលសាសង កុំមេមាសមិត្ត ព្រួយ ចិត្តឡើយហោង បងពុំអាចបង់ ចិត្តចាប់ទោសា ។ ព្រះសុវណ្ណពង្ស នាងនាថវរវង្ស សំណេះបវរា ស្រេចស្ដេចផ្ទមផ្ទល់ បរមសុខា លង់ លុះសុរិយា រៀវរះបូព៌ាបាន ។ ស្ដេចគង់ផ្ទមផ្ទល់ ទីងនាងនិមិលត្របេះ រូហោន ចុះចាកពិកព ជាមួប់សួគ៌ឋាន ផ្ទឹមទីងកល្យាណ ឥតមានសៅហ្មង ៗ អស់ស្រីស្រិង្គារ យល់ព្រះភូបាល ទីងនាងទួទល្អង គង់ផ្ទឹមល្អល្អះ ត្របះកន្លង កំលៀងទាំងសង កេះប្រាប់គ្នាថា ។ ហៃអស់ទាំងមេ មើលហើញឬទេ ព្រះរាជក្សត្រា យើងដាក់យន្តត្រូវ ឈាមនៅធរណី ពុំក្ស័យជីវី ជីវិតមរណា ។ ឥឡូវរួចរស់ រូបរាងស្រេចស្រស់ មកនៅផងគ្នា ឥតអគ្គីកល អញថ្លល់មហិមា ក្រែងប្រុសទ្វេហា ស្ដាប់មួយគង់មួយ ។ ដូចេះអស់ឯង នៅចាំកន្លែង បន្ទោះរង្គួយ សព្វប្រកមាតិ ចាំរាមុខក្រោយ ប្រហែសកុំធ្លោយ ក្រែងលបរត់

ផ្កាត់ ៗ អញ្ជើញនឹងយាត្រា រត់ខ្មីម្នីម្នា ទៅទូលមហាក្សត្រ ជាព្រះ
បិតា កាលគ្រានោះថ្កាត់ បើពុំប្រយ័ត្ន ទោសដល់អាត្មា ៗ កាល
នោះកិលៀង រត្នរត់បំព្រៀង បំព្រឹមម្នីម្នា ស្រេចដល់ព្រះបាទ នរាថ
ថ្លៃថ្លា ហត់ហបទូលថា បពិត្រក្សត្រក្សាន្ត ៗ មានមនុស្សព្រៃណា
ចរចូលទាំងឆក- ត្រីដល់រាជស្ថាន ព្រះរាជបុត្រី ប្រិមប្រិយកល្យាណ
បិត្តធំហៅហ៊ាន អន្ទុយផ្ទឹមផ្ទាល់ ៗ ព្រះបាទកូធរ ស្ដាប់កិលៀង
ទូល ក្រេវក្រោធឆេះឆុល ថាយើសេនា ហោធាបរពល ចាប់រាក់ហាល់
កំហូចឲ្យបាន ៗ ទាំងប្រុសទាំងស្រី យកមកធ្វើគ្គី ទុកទាំងពីរ
ប្រាណ ឲ្យស្លាប់ក្នុងស្រះ ប្រាក់កំមាន់ ប្រណីណាបាន ឆាប់ ៗ
រួសរ៉ា ៗ

## បទពំនោល

កាលនោះអស់ទាំងសេនា ស្ដាប់ម្នីម្នា ក្រាបលាចរចុះឆាប់
រៃ ៗ បរពលអស្សុរច្រើនក្រៃ កាន់ទួនទង់ជ័យ ប្រកិតអាវុធផ្កាញផ្កា ៗ
កាន់ដាវលំពែងធ្នូ ខែលខែងងើរ ក្រពាក្រកើននីរភ្ញុក ៗ ពល
ផងអឺងកងគគឹក ចូលទោមពទ្ធក ប្រាំពីរជាន់ជុំក្រាស់ក្រៃ ៗ ក្សិណ
នោះក្សត្រត្រីស្រីថ្លៃ យល់ហើយកិតភ័យ ក្រាបទូលព្រះរៀមបេស្ដា ៗ
បពិត្រគួរយើងលេលា រត់ជៀសបេស្ដា យកក្សាសាមាន្យហៅហាន ៗ
ចោមជុំមណ្ឌលរាជស្ថាន សមស្លាប់ពុំខាន ម្ចាស់អើយខ្ញុំខ្លាចពេកក្រៃ ៗ
ព្រះបាទនរនាថជៀសជ័យ យល់នាងស្រីថ្លៃ ភ័យញ័រអស់អង្គអាត្មា ៗ

ស្តេចលោមស្រីគន់ស្នួនក្លា ព្រះហស្តប្រាប់ បបោសអង្អែលអគ្គស្រី ។
មានព្រះបន្ទូលវិង្វី ប្អូនអើយកុំបី គិតខ្លាចអំណាចយក្សា ។ បង
ពុំព្រួយព្រឺរោមា ជាបងជានា ផ្តាញរាក់ឲ្យក្ស័យនេះម្តង ។ កុំថា
ប៉ុណ្ណោះឡើយហោង ទោះច្រើនរំលង ដល់មុនសែនកោដិសមុទ្រ ។
បងផ្តាញឲ្យលាញព្រាកដ កុំមាសបរិសុទ្ធ ម្ចាស់ម្លព្រួយព្រះបិន្ដា ។
បន្ទូលស្រេចហើយក្សត្រា ចាប់ផ្ទួសរថា ផ្ទែងផ្តាញអសុរទ្រឹស្តយ្ឃន៍ ។
សូរសព្ទអឺងអាប់កន្ទង ស្គុតស្លាប់ប្រគង ខ្លះរស់រួតរត់ពួនទៅ ។
ជជ្រុលជជ្រកសោជៅ ក្អកសក្អកខ្មៅ ចូលទូលព្រះបវរបិតា ។ បពិត្រ
ជម្រិតមនុស្សមោហា មានឫទ្ធិបេស្តា ផ្ទែងផ្តាញអស់ពលក្រិណក្ស័យ ។
ព្រះបាទបីតាដៀស្តជ័យ ក្រេវក្រោធពេកក្រៃ ថាយើអស់ទាំងសេនា ។
ពួកពលអសុរយក្សា ឆាប់វៃម្ចម្មា អញចេញតតេជះដៃ ។ ខ្លាចអ្វី
វាមនុស្សបព្រៃ តែម្នាក់ឯងនៃ ចូរទោមពិឃាតមរណា ។ កាល
នោះមានអគ្គសេនា មួយមានប្រាជ្ញា បេះសិល្បក្សត្រាឈ្លាសវៃ ។
ជាធំលើសអស់មន្ត្រី ទូលក្សត្រអសុរី បពិត្រព្រះបាទបមពៅ ។ កុំ
ព្រួយព្រះទ័យស្តេចទៅ តាំងតយុទ្ធនៅ មនុស្សម្នាក់កំឡោមោហា ។
ជាខ្ញុំឯងអាចឆានា ចូលចាប់មនុស្សា យកមកថ្វាយមហាក្សត្រថ្លៃ ។
ព្រះបាទបិត្រាដៀស្តជ័យ ស្តាប់ពាក្យមន្ត្រី វិចិត្រសេនាក្រាបទូល ។
ត្រាស់ថាឡោះបាកុំយូរ ចូលចាប់កុំផ្សូរ កុំផ្សង់បង្អង់លង់ឡើយ ។
វិចិត្រសេនាស្តាប់ហើយ លាក្សត្រត្រាណត្រើយ ចរចូលដល់ឋាន

អាត្មា ៗ លុះល្មមឬក្សពារពេលា វិចិត្រសេនា យកក្បាលព្រាយ បីមកកល់ ៗ ដើងគ្រានស្រេចបានអសុរ យកថ្នាំមកដល់ តាំងពី-ធីស្រេចហើយណា ៗ វិចិត្រមន្ត្រីលីលា ចរបូលម្ទីម្ទា លុះដល់ក្រ-ឡាបន្ទុំ ៗ យក្សសែបគាថាអាគម ទិព្វមន្តសណ្តំ ព្រះពោធិសត្វ សេដ្ឋា ៗ ហេតុតែគេជះគាថា សណ្តំយក្ស ស្តេចផ្ទុំលង់លក់ពេកក្តាត់ ៗ ព្រមតាំងនាងនាថស្រីរតន៍ ផ្ទុំលង់លក់ក្តាត់ ពុំភ្ញារពុំភ្ញាក់ឡើយណា ៗ វិចិត្រមន្ត្រីយក្ស ដឹងជាក្សត្រា ត្រូវស៊ីលសណ្តំស្រេចស្រាប់ ៗ យក្សម្ទីម្ទាប្រញាប់ ចូលចាប់ទុបខ្លាប់ ហិចពោះកណ្តាលវេហាស៍ ៗ ដាក់ដល់មណ្ឌលក្សត្រា ឥស្សរយក្សលុះព្រឹកស្រេចស្រោងទទ័យ ៗ ព្រះបាទបិត្រា វៃៗចេញចុងរោទ៍ជ័យ ទតយល់ព្រះបាទពេជា ៗ បន្ទូលថាហៃសេនាវិចិត្រ យក្ស ចូរស្រាយសណ្តំចេញខ្ទី ៗ វិចិត្រស្តាប់ហើយរឹងរៃ សូត្រសារ្ស សិល្បសេយ ទើបព្រះពោធិសត្វា ៗ តើនឡើងនាកាលនោះណា ព្រះបាទក្សត្រា ទតយល់អសុរឃើសឃ្មង ៗ ពុំព្រួញពុំព្រឺប៉ុនល្អង ក្សត្រាបរ្សប្លង នឹកក្តុងព្រះរាជហឫទ័យ ៗ នេះសមយក្សចង្រៃ លបចូលដល់ញ ក្រឡាបន្ទុំសយនា ៗ សណ្តំអញពុំដឹងការណ៍ ចាប់យកអាត្មា អញមកដល់ទីនេះថ្វាត់ ៗ ប្រែប្រឹងព្រះកន្ត្រាមហាក្សត្រ រុងរឿងល្អក្តាត់ពុំគោតពុំក្រេងយក្ស ៗ ក្សណនោះព្រះបាទបិត្រា បើកបន្ទូលថា ហៃមនុស្សចង្រៃជួជាតិ ៗ ចូរមឹងលើកដៃវាត អញពុំពិឃាត សម្លាប់បំបាត់ជន្មា ៗ បើមឹងមុខរឹងមហិមា ពុំរវន្ទា សមក្ស័យជីវិតពុំលែង ៗ ម្តេចមឹងពុំខ្លាច

[illegible]
លេខចូល :

ប្ដីខ្វែង ពន្ទឹកលើសលែង គួរសូមអង្វរទោសា ។ ស្ដេចស្ដាប់សា
សព្វវាចា យក្សក្រេវក្រោធា ក្សត្រាបន្ទូលសាសនី ។ ហៃស្ដេច
កំឡោទ្រឹស្ដឃ្នង បានទៅប្រឡង ប្រឡែងដណ្ដើមជោគជ័យ ។
ទើបរាប់ក្សត្រីប្ដីក្រៃ ឥឡូវនេះនៃ លបលួចបោះបង់និទ្រា ។ រាប់
អ្វីជាមានប្ដី បោះបង់និទ្រា កំសាកកំសោយស្ទើស្រី ។ អញពុំ
ត្រឹមប៉ុនកេសី ខ្លាចអ្វីបារមី លួចស្រែសណ្ដំនិទ្រា ។ មិនដូចសត្វ
ខ្លួនទេណា រកបរិភោគា តែយប់ថ្ងៃដេកពួនទៅ ។ បេញថ្ងៃខ្លាចក្អែក
ឃោរឃៅ ដូចមិនកំឡោ កំលាំងខ្សោយណាស់ស្ទើញី ។ បើមិនលើក
រាជបុត្រី ផ្ទំទីនអញខ្ចី នោះទើបអញវេទ្នា ។ តាមច្បាប់សណ្ដាប់
ក្សត្រា ពីព្រេងនាយណា ទំនុំទំនៀមក្សត្រផង ។ ប្រពន្ធឲ្យអញព៉ប់រង
សំពះទន្ទង អង្វរសូមសុំទោសា ។ ខ្លាចក្រែងតែក្សត្រឯណា មួយ
ឥតបេស្ដា នោះគួរខ្ញុំខ្លាចក្សិណក្ស័យ ។ សំពះសូមសុំទោសពៃរ៍
រីអង្គអញនៃ ជាក្សត្រមានប្ដីបេស្ដា ។ អញពុំសំពះឡើយណា
កុំមិនវាចា អញពុំខ្លាចប៉ុនកេសី ។ កាលនោះបិត្រាអសុរី ក្រេវ
ក្រោធឥតឥបី ឥតបើផ្ដូរផ្ដើមឧបមា ។ ស្ដាប់ព្រះពោធិសត្វា តិះ
ដៀលបេ្ខះណា ញ៉័រអង្គទន្ទល់ពេកក្រៃ ។ រាមើលគោងទ្រឹស្ដ៏ចង្រៃ តូចប៉ុន
មេដៃ អាងអួតប្ដីបេស្ដា ។ មើលមុខមាត់មិនដូចស្វា អាងអួត
ប្ដី ឆ្មោះឲ្យគេចាប់បានថ្វី ។ ថ្វីមិនតតាំងឲ្យហើយ អង្គុយព្រងើយ
ធ្វើមុខដូចក្អែកសាមាន្យ ។ ពះអស់គ្នាយើងគ្រប់ប្រាណ ចាប់នាំទៅថ្កាន

ដាក់ទ្រុងដែកឲ្យជាប់ក្រៃ ៗ ដាក់គុកប្រាក់ឲ្យក្ស័យ ក្នុងទ្រុងនោះ ផែន កុំកាប់សម្លាប់ឡើយណា ៗ ទើបអស់ពេជ្ឈឃាតម្នីម្នា ចូលចាប ពជា ដូចព្រះបង្គាប់ឆាប់ក្រៃ ៗ ខ្វះទាញកន្ត្រាក់ដើរដៃ កើបបេញ ឆាប់ពៃ ដាក់ស្រោះប្រពាក់សោតខ្លាប់ ៗ ដាក់ទ្រុងដែកជាប្រញាប់ យក្យបាប់ខ្ជាន់ខ្ជាប់ ប្រដាប់ប្រដាការក្រៃ ៗ

## បទកាកគតិ

ព្រះពោធិសត្វ ពន្ធកបរមត្ថ សោយសោកលើសលែង ទុកម្ម តៀរពិត គំនិតពីព្រេង មកកម្មមាក់ឯង ក្នុងទ្រុងយក្សា ៗ ទុព្រះ ជនក ជននៅស្រុក នគរនាយណា ទន្ទឹងកូនបាត់ លង់ក្តាត់សោកា មើលផ្លូវបុត្រា កូនកាលណាដល់ ៗ ពុំដឹងជាក្ស័យ ជីវិតប្រល័យ កូនរងទុក្ខខ្វល់ ទុក្ខទោមនស្ស មរណាពុំយល់ ចោរខ្មោចដូចគល់ ដូចគេសាមាន្យ ៗ ស្តេចសោករីងរោក សែនសល់អាមោក សន្ធប់ ប្រះប្រាណ ស្មើរក្ស័យបង់បាត់ ជីវិតវិញ្ញាណ សូន្យសុងនៅឋាន រូប រងវេទនា ៗ ក្សណៈនោះនាងនាថ តើនមើលព្រះបាទ រកព្រះពជា ពុំយល់ឡើយនៃ ស្រីថ្ងៃសោកា ញាប់ញ័រអង្គា ភ័យគិតលើសលន់ ៗ នាងយល់ធ្វូស ច័នជ័យបវរ និត្យនៅខាងអង្គ គិតថាបើក្សត្រ បរ កាត់ត្រេចត្រង់ នគរហើយទ្រង់ យកធ្វូច័នថ្វា ៗ ទៅផងពុំខាន ឥឡូវនេះមាន ហេតុកើតយល់ជា វិចិត្រមន្ត្រី សេនិយនោះរា ព្រោះ បង់និទ្រា សណ្តំយកទៅ ៗ ថ្វាយព្រះបិតា ឥឡូវនេះណា គួរអញ

សំដៅ ចូលទូលព្រះបាទ នរនាថបមពៅ គិតស្រេចស្រីពៅ ស្រី

ពុំសោកា ៗ យាសយាន៍ចរបូល ទៀងទៅក្រាបទូល ព្រះវរបិតា

នាងទៅទាំងទុក្ខ សម្រក់នេត្រា ដល់ស្រេចវន្ទា ប្រណម្យថ្វាថ្ងៃផង

បពិត្រព្រះបាទ បិតានរនាថ ជ.កិជាគម្ពង កូនបានជាខុស លើស

លោះក្រៃលែង ពុំគោតពុំក្រែង បុណ្យបារមិតា ៗ ឥឡូវស្ដេច

ក្រោធ ក្រេវក្រៃពិរោធ ពោះបង់និទ្រា ចាប់ប្ដីខ្ញុំបាន នាំថ្កានថាន

ណា សូមទ្រង់មេត្តា អាសូរប្រណី ៗ កូនកាលនេះម្ដង ឲ្យបាន

រួចវង់ រួមរ័ក្សមេត្រី បើពុំមេត្តា កាលគ្រានេះនៃ កូនក្ស័យជីវី ជី

វិតមួយគ្រាណា ៗ ទឹងប្ដីខ្ញុំនៃ ខ្ញុំរស់នៅថ្វី រស់រូបពុំក្សាន្ត សូម

មេត្តាប្រោស ថ្វាយទោសប្រធាន ពុំបេរក្សត្រក្សាន្ត ទ្រង់ព្រះមេត្តា ៗ

កាលនោះព្រះបាទ បិត្រានរនាថ ជាព្រះបិតា ស្ដាប់បុត្រទៀងទូល

ដោយនៅវាចា សូមសុំទោសា ស្ដេចក្រេវក្រោធក្រៃ ៗ ដេរនាង

ជាយា មេចោរពេស្យា ចិត្តកាចបង្រៃ គិតខ្វាសមេបា ចោរសា

មាន្យក្រៃ យកប្រុសតិរ្ច្ឆយ ជាមនុស្សប្រុស្សា ៗ ចិត្តធំពេកក្ដាត់

វាហ៊ានបំបាត់ ជីវិតយក្សា ពលពាលសេនិយ អសុរីមរណា ហ៊ាន

ហ៊ានលេលា មកសូមទោសពៃរ៍ ៗ មេចោរដកទង អញចាប់ក្បាល

ហាង ទាំងពីរនោះនៃ ចោរជួអបលក្ខណ៍ កន្ទ្រាក់ទាញដៃ ទៅធ្វើ

ទោសពៃរ៍ ឥឡូវនេះណា ៗ នាងស្ដាប់ព្រះសូរ បិតាបន្ទូល

ខ្វាសនឹងធីតា នាងលើកបទបង់ តម្រង់លេលា លុតលាបិតា ដល់

ប្រាសាទស្រី ៗ នាងនាថទួញយំ ឱព្រះឱត្តម ផ្ទាប់វែងមេត្រី ឥឡូវក្សត្រថ្ងៃ ក្សិណក្ស័យជីវី ឬមួយភូមី រស់រូបជន្មា ៗ បើក្សត្រ ក្សិណក្ស័យ ខ្ញុំសូមប្រល័យ ជីវិតមរណា មួលមួយព្រះអង្គ បើ គង់ជន្មា រស់រងវេទនា លំបាកពេកក្រៃ ៗ ហើយនាងទងវង សោយសោកគន្ធង កន្ទេងល្ហិតល្ហៃ ពុំល្ហើយពុំល្ហៃ ទំនេហ្ឫទ័យ ស្ទើរនឹងក្សិណក្ស័យ ជីវិតមរណា ៗ លុះសាយណ្ហោ ទន់ទៀប ទៅឯ ទីទិសមជ្ឈិមា ជួបចូលពត្រី ស្រស់ស្រីសោភា នឹងបរលេលា តាមរកភូមី ៗ នាងលើកទសករ បង្គំថ្វាយវរ សម្ដេចកោសី ប-ពិត្រព្រះឥន្ទ្រ នរិន្ទ្រជៀស្ឋជ័យ សូមស្ដេចអភ័យ ទោសដល់ខ្ញុំណា ៗ ជួយខ្ញុំស្មោះស្មាន ខ្ញុំតាមក្សត្រក្សាន្ត គម្ដងក្រឡា សូមឲ្យធ្នូសរ បវរខ័នថ្វា នាំខ្ញុំលេលា ឲ្យដល់ភូធរ ៗ ហើយឲ្យពលយក្ស ដេក កុំឲ្យភ្ញាក់ ស្រេចខ្ញុំចេញចរ ឲ្យឃើញព្រះបាទ នរនាថបវរ កុំឲ្យ អស់នរ អ្នកផងឃើញខ្ញុំ ៗ ផ្សងស្រេចពីតា ចាប់ធ្នូខ័នថ្វា ស្រេច ស្រាប់ពិតពុំ លង់ឡើយលីលា យាត្រាចុះអំ- ពីរាជបន្ទុំ ដល់ដែន ពសុធា ៗ នមស្ការភូបាល វិសេសវិសាល ស្រេចបរលេលា អស់ពលយក្សយល់ គ្រៀវក្រាស់ត្រៀបត្រា ដេកសព្វមាគ៌ា ពុំ ភ្ញារភ្ញាក់ប្រាណ ៗ ស្រេចវរជាយា យាងយាសយាត្រា ទតយល់ ក្សត្រក្សាន្ត ក្នុងទ្រូងដែកដាក់ ប្រាក់ពុំមាន រន្ធៀសប្រែប្រាណ ក្រ ក្រៃមហិមា ៗ នាងនាថទួញយំ ព្រះហស្ដផាលដំ ទ្រូងទ្រឹងសោភា

បម្រះនទៀល រមៀលអង្គា ទួញទូលក្សត្រា ឥសូរសិរសី ។ ប-
ពិត្រព្រះបាទ ខ្ញុំខំសង្វាត ទៅដល់ព្រះបី- តាទូលសូមទោស ពុំ
ប្រោសឡើយនៃ ខ្លួនខ្ញុំរំពៃ រំពឹងមរណា ។ ឥឡូវខ្លួនខ្ញុំ សូម
ស្លាប់ទឹងអ- ម្ចាស់ថ្ងៃសោភា តាមកម្មពៀរព្រេង នោះឯងកាលគ្រា
ឥឡូវកុំឃ្លា កុំឃ្លាតក្សត្រថ្ងៃ ។ ស្ដេចស្ដាប់ជាយា បន្ទូលត្រាស់
ថា បងអរគាប់ថៃ ចិត្តប្អូនពុំង៉ា ស្នេហាមូលមៃ ត្រីត្រែកហឫទ័យ
ស្លាប់រស់ផងគ្នា ។ ស្ដេចយល់ក្សត្រី ចូលកន្ទុំទ្រុងខ្ញី មូលទឹកជា
ធូសព្រះច័ន សោភ័ណថ្ងៃថ្ងា ទុកដាក់លាក់ជា ម៉ត់ចត់ឥតហ្មង ។
លុះព្រឹកស្រេបស្រោង សុរិយាបំព្រង អស់ពលព្រិទ្ធផង យង់
យល់នាងនាថ គ្រាកាលទង់វង់ គង់ផ្ទឹមព្រះបង់ ព្រះបាទពជា ។
យកព្រះតំបូលទូល ចំត្រាឥសូរ ទូលដោយវាចា ក្សត្រយកព្រគៀវ
គ្រោង ពិរោធមហិមា ថាពួកសេនា រួសឆាប់វៃៗ ។ ចាប់ចោរអ-
បលក្ខណ៍ ទុកទាញកន្ទ្រាក់ ដាក់ទោសដាក់ពៃរ៍ យកទៅសម្លាប់
ឲ្យឆាប់នាថ្ងៃ នេះកុំសង្ស័យ ឆាប់ៗម្ចីមា ។ មន្ត្រីផងស្ដាប់ រៀប
ពលប្រញាប់ ចូលចោមត្រៀបត្រា ប៉ង់ទឹងចូលចាប់ ខ្ជាន់ខ្ជាប់
មហិមា ព្រះបាទពជា បន្ទូលថាហៃ ។ អាមកប្រាជ្ញា មកចាប់
ជាយា ពន្ទឹកក្រាស់ក្រៃ ចូរអាលីលា យាត្រាឆាប់វៃ ប្រាប់ម្ចាស់
អាទៃ ឲ្យមកម្ចីមា ។ ទើបយកក្សត្រី បានដូចសេចក្ដី បំណង
ប្រាជ្ញា អស់អាកុំខំ សមក្ស័យមរណា ពុំខានឡើយណា ឥឡូវ

នេះនៃ ៗ បន្ទូលម្ល៉ោះស្រេច ក្សណនោះទើបស្ដេច ហូតព្រះខ័នជ័យ កាប់ទ្រង់ខ្ចាត់ខ្ចាយ អន្តរាយឆាប់ក្រៃ កាប់ពលយក្សក្ស័យ ជីវិតមរណា ៗ ខ្លះរស់ពុំមរណ៍ រួតរត់ចេញចរ ចូលដល់បិត្រា ក្នែកសរសើតស្ទក់ អាក្រក់នាំគ្នា ចូលដល់ទូលថា បពិត្រក្សត្រថ្លៃ ៗ ឥឡូវនេះណា មនុស្សចោរមោហា កំណាចកាចក្រៃ ប្រះទ្រង់ដែកផ្ចាក់ ផ្កាយធ្លាក់ណាស់នៃ នាំពលបុត្រី ចរចេញសោះសា ៗ បំផ្លាញអស់ពល យក្សច្រើនសល់ ស្លុតស្លាប់ត្រៀបត្រា រស់រួចតែខ្ញុំ ពិតពុំមរណា។ ចូលទូលរាជា សូមជ្រាបព្រះទ័យ ៗ

បទពំនោល

ព្រះបាទឥសូរជៀស្ឋជ័យ ស្ដាប់ហើយក្រោធក្រៃ ចាប់ពេជ្រត្រីក្រតា ៗ ស្រៀវស្រែកសម្រែកសោះសា រ៉ុយអស់សេនា អាមាត្យបរពល ឆាប់ក្រៃ ៗ អញចេញចាប់ចោរចង្រៃ ឥឡូវនេះនៃ កុំផ្សង់ឲ្យលង់ យូរឡើយ ៗ អាមាត្យបន្ទូលហើយ ណាក្សត្រត្រាណត្រើយ រួតរត់បរចេញយាត្រា ៗ បរពលអាសុរយក្សា ខ្នាន់ខ្នាប់ត្រៀបត្រា ពាសពេញពាំងផែនប្រិថពី ៗ កាន់ទ្រួនទង់ជ័យត្រី អួតអាងឫទ្ធី មនោមានះឥតក្ញុក ៗ សេនាកាំភ្លើងគគឹក ដាត់ធំស្រមឹក ស្រមូវស្រមាក់អួតអាង ៗ សេនាលីគ្រឿងប្រឆាំង អនេកកស្តុតាង ប្រដាប់ប្រដូចពលមារ ៗ សេនាអាងអួតឫទ្ធា ដាត់ធំមហិមា មមីងមមាំងក្លៀវក្លា ៗ សេនាសឹងថ្មើរជើងដារ កាន់ទ្រង់ត្រិតា ក្រឯងក្រអាងមានមិត្ត ៗ ស្ទៀកខោស្នាប់

ក្តៅរួតរឹត គ្រុនដែកគាស់គិត ប្រកិតប្រកាន់ផ្ទុស្នា ៗ សាហា
សាហាវខ្លាំងក្លា កាន់អាវុធា ចូលទូលព្រះបាទរាជា ៗ បំរាត់សូរម្មា
កាន់ពេជ្រក្រទា គ្រវីសង្ហាគ្រៀងពល ៗ សេនាយោធាអសុរ លើក
ទ័ពស្រេចដល់ ចូលចោមព្រះបាទចក្រី ៗ ស្តេចយល់អស់ពលច្រើន
ក្រៃ ឥតក្តុកនិរភ័យ គ្រវីព្រះខ័នចូលយុទ្ធ ៗ កាប់ពលអសុរ
ស្លាប់សុត មមីរមមុត ក៏ស្លាប់រណែលត្រៀបត្រា ៗ ព្រះបាទឥសូរ
យក្សា យល់ពលមរណា ក្រោធាពន្លឹកពេកក្រៃ ៗ ចាប់ពេជ្រគ្រ-
វីវិលវៃ ចូលតតេជដៃ បំណងសំពងរាជា ៗ ឲ្យក្ស័យជីវិតមរណា
ព្រះបាទក្សត្រា គ្រវីព្រះខ័នផាត់ផាយ ៗ យក្សានឹកក្តៅក្រហាយ ក្រហល់
អស់កាយ មហាក្សត្រប្រហារវិលវៃ ៗ សូរសព្ទអឺងអាប់ពេកក្រៃ កក្រើក
ដល់ព្រៃ ព្រះហោមពាន្តជលធី ៗ អ័ព្ទអាកាសនភី ដោយតេជឫទ្ធី តេ-
ជះតបោចេស្តា ៗ យក្សក្រេវក្រោធក្រៃក្រទា នេត្រចាលសោះសា ក្រឡេក
ក្រឡោតសំឡឹង ៗ ស្តេចចាប់ព្រះខ័នវ័ធវ័ង ក្សត្រិយ ក្សប្រុងប្រឹង លើក
ពេជ្រទប់ខ័នរាជា ៗ ស្តេចសោតហាហួតខ័នថ្វា កាត់សិរអសុរា ដាច់ធ្លាក់ក្នុង
ឈាមអស់ពល ៗ សិរយក្សហៀរហាក់ដូចខ្យល់ លោលោតឡើងដល់
សុរធ័សិរាជាប់ក្នឹង ៗ យក្សាពះពារខេរខឹង ចូលយុទ្ធប្រកឹង ប្រកួតប្រកាប់ក្ស
ត្រា ៗ ស្តេចកាប់យក្សស្លាប់ជាតិជា ៧ដងអសុរាកើតជាមួយវយ សាមសិប
អង្គព្រាណដាសដានប្រញាប់ ប្រញាយសន្ធាប់សន្ធឹកពន្លឹកឫទ្ធី ៗ កក្រើក
រំពើកធរណី លើកពេជ្រគ្រវី ធនិះធង៉ះចូលយុទ្ធ ៗ ស្តេចយល់អសុរមា-

សមុត ចូលតោមពង្សព្រុទ្ធ ស្តេចហូតព្រះខ័នជ័យថ្ងៃ ។ កាប់យក្សអប-

លក្ខណ៍ចង្រៃ វិនាសក្សិណក្ស័យ ជីវិតមូលមួយមរណា ។ ក្សិណកើត

វិលវិញទៀតជា រូបធំមហិមា ប៉ុនភ្នំសុមេរុរាជ ។ ក្បាលជាមួយពាន់ឯង

អាច ប៉ុទ្ធអំណាច កំណត់ហត្ថាពីរពាន់ ។ រត់ចេញឃ្លាតខ្លាញ់

ស្រួពន់ ទូងគើរលាន់ សន្ធឹកសន្ធាប់សោះសា ។ កក្រើកកំពើក

ពសុធា ផ្អើលពលអសុរា យក្សច្រាំសែនស្រមុទ្ធ ។ ធំៗមួនមាំ

ក្រកុត កាន់គ្រឿងអាវុធ ប្រកិតប្រកាន់ដោយដៃ ។ បរបួលមក

មូលក្រាស់ក្រៃ បង្គំអសុរី បពិត្រព្រះបាទរាជា ។ មានហេតុកិនកេច

ម្តេចម្តា ស្តេចក្រេវក្រោធា ទទូងគើរខ្ញូរខ្ញូរ ។ កក្រើកកំពើកញាប់ញ័រ

បរពលខ្សៀវខ្ញូរ លុះមកដល់ព្រះរាជា ។ កាលនោះព្រះបាទបិត្រា

ឥស្សូរយក្សា យល់ពលអសុរទ្រើសឃ្លង ។ ប្រាប់ថារុំយសេនាផង

មានមនុស្សម្នាយហោង មកលួចព្រះរាជបុត្រី ។ ហើយផ្លាញអស់ពល

សេនីយ ស្លុតស្លាប់ក្រាស់ក្រៃ កណ្តាលសុមេរុរៀណរង្គ ។ គ្នាយើង

ឆាប់ឡើងកុំលង់ ចូលតោមចាប់អង្គ យកមកពិឃាតជន្មា ។ អស់ពល

សកលយោធា ស្តាប់ហើយម៉្មឹម៉្មា ចូលតោមអឹងអាប់ច្រើនក្រៃ ។

ព្រះសុវណ្ណហង្សជៀសជ័យ ឡើងគង់មនោម័យ ទន្ទឹមទឹងអគ្គជាយា ។

ព្រះមហាក្សត្រថ្លៃប្រវា ចាប់ធ្នូសរថ្វា ផ្ទង់ផ្លាញអសុរយក្សក្ស័យ ។

ស្លុតស្លាប់មរណាណាស់នៃ ខ្ទះរស់កិតក័យ រួតរត់ជាយផុតអាត្មា ។

កាលនោះឯអង្គបិត្រា យល់ពលយក្សា ស្លុតស្លាប់វិនាសក្សិណក្ស័យ ។

ចាប់ធ្នូសរស័ក្តិជៀសជ័យ ក្រៅក្រោធពេកក្រៃ កន្ត្រាន់ទន្ត្រាំពសុធា ។
ក្សិណនោះសុវណ្ណជាយា យល់ព្រះបិតា ក្រៅក្រោធរន្ធត់អស់អង្គ ។
នាងទូលបពិត្រវរវង្ស បិតាសូមទ្រង់ សណ្ឋិតអត់ទុនទោសា ។ កូន
បានជាខុសហើយណា សូមព្រះបិតា រំសាយព្រះក្រោធក្សេមក្សន្ត ។
បើក្សត្រពុំស្ដាប់ហើយហ៊ាន ក្រែងតពុំបាន ក្សត្រក្សាន្តដល់ក្ស័យមរណា ។
ព្រះបាទឥស្សូរយក្ស ឮកូនស្ដីថា រឹងក្រៅរឹងក្រោធសែនទ្វី ។ ថាហៃ
មេចោរអប្រិយ ខ្លួនឯងជាស្រី ពុំគន់ពុំគិតអាត្មា ។ ឯងឲ្យសហាយ
ឯងណា សម្លាប់ឃោធា ពោរពាសកណ្ដាលវៀណរង្គ ។ ហើយ
ឯងសាមាន្យជៀលអង្គ អញឯងទ្រើសទ្រង់ ប្ដីគេជះបេស្ដា ។ សម
នឹងក្សិណក្ស័យមរណា ទាំងពីរអង្គារ ឥឡូវនេះពុំលែងឡើយ ។ នាង
ស្ដាប់បិតាត្រាណត្រើយ ខ្វល់ណាស់ពុំស្បើយ នាងនាថស្ងៀមស្ងាត់
និត្យនៅ ។ ព្រះបាទបិត្រាបមបៅ ចាប់សរខ័នកៅ- ទណ្ឌស្រេច
វៀសវៃសោះសា ។ តម្រង់ព្រះអង្គហើយណា ថ្វីងជានាំគា ក្សត្រា
ថ្វីងជាសរសង ។ ជាគ្រុឌប្រៀវប្រុតហោះផ្សង តៀងចាបនាងផង ក្រ
ញឹកក្រញ៉ីចាប់ស៊ី ។ យក្សថ្វីងជាអគ្គី ស្ដេចជាជលធី រលត់រលាង
ភ្លើងយក្ស ។ អសុរមហិមាជៀងជាក់ ថ្វីងជាសរស័ក្តិ បង្អោរជា
ភ្លៀងសព្វសាយ ។ ក្សត្រាថ្វីងជាព្រះពាយ បោកបក់ផាត់ផាយ រំលាយ
រំលាងភ្លៀងបាត់ ។ យក្សរឹងខេរឹងខាំមាត់ ស្ដេចថ្វីងសរកាត់ ផ្ដួល
ផ្ដាច់អសុរយក្ស ។ កក្រើករំពើកអស្ចារ្យ សមុទ្ទជលសា រលកបោកបក់

ខ្ញ័រខ្ញុរ ៗ បពិតរន្ធត់ញាប់ញ័រ ត្រឹកក្បាលតាវល្វិ កក្រើករំពើកសព្វ សល់ ៗ ហោមពាន្តសួគ៌ស្ថានមណ្ឌល កក្រើកដូចកល ឥន្ទព្រហ្ម ឲ្យពារគ្រប់គ្នា ៗ ព្រះសុវណ្ណហង្សថ្ងៃថ្វា មែនមានបុត្តា យកក្បាលដួល ដល់ធរណី ៗ

## បទព្រហ្មគីតិ៍

ក្សិណព្រះបាទបិត្រា- ស្តាយក្សត្រីសរដ័យ ព្រះអង្គពុំទាន់ ក្ស័យ អស់ព្រះជន្មនៅឡើយណា ៗ ព្រះបន្ទូលហើយហៅ ហៃ កូនពៅមាសពុំង៉ា បូរនាងមកឆាប់ភ៉ា ទាន់ឪពុកនេះរស់នៅ ៗ ឪពុកមានកម្មព្រេង មកវេទ្ធនាស្រីពៅ នាំបិត្តខឹងយោរយៅ ពុំគិតក្ស័យនៃជន្មា ៗ កូនអើយរាជសម្បត្តិ ប្រជារដ្ឋរាស្ត្រគ្រាមា ឲ្យ ប្តីនាងធីតា គ្រប់គ្រងអស់មុខមន្ត្រី ៗ ឪពុកនឹងមរណា កូនពុំង៉ា នាងស្រស់ស្រី បូរមាសមេប្រាប់ប្តី កុំឲ្យអន់អាក់ចិន្តា ៗ ហៃបាសុ- វណ្ណហង្ស អម្បូរពង្សពូជពុង្ធា ឪពុកផ្ញើនគរ រាស្ត្រប្រជាពលច្រើន ផង ៗ ហើយផ្ញើរាជបុត្រី ដោយពិសីឲ្យអ្នកគ្រង រាជាក្សត្រប្វាស់ ប្វង ជាឥស្សរាស្ត្ររដ្ឋា ៗ ស្តេចបន្ទូលផ្តាំម៉្ញោះ ទើបក្សិណនោះ ពិសសារថ្វា ឡប់ឡើងផ្សព្វផ្សាយផ្សា ចប់ពុំបានឡើយក្សិណក្ស័យ ៗ នាងកេតសុរិយង្គស្តាប់ បណ្តាំសព្វស្រេចហើយនៃ យល់ជាក្សត្រក្សិណ ក្ស័យ ជីវិតពុំរស់រូបបាន ៗ នាងលាព្រះវៀមរ័ត្ន បរបូលថ្វាត់ដល់ បិតា ក្រាបក្រោមព្រះបាទា គឹងឱរាខ្វាបផ្សាយ៉ំ ៗ ឱព្រះអង្គមានគុណ

គុណាមហាធ្ងន់ថ្ងៃឧត្តម ម្តេចឡើយស្តេចមកផ្ដុំ លើក្រឡាមហាប្រិថ-ពី ។ ឱព្រះអង្គក្សត្រថ្ងៃ បើនឹងក្ស័យទៅក្នុងទី ប្រាសាទរ័ត្នកែវមណី ជាបន្ទុំព្រះកូបាល ។ ឱកម្មអីព្រះអង្គ ស្តេចពុំទ្រង់ព្រះសទ្ធា កូនបូលទូលបិតា នោះសូមឃាត់ពុំឲ្យក្រោធ ។ ស្តេចពុំស្តាប់ខ្ញុំនៃព្រះជៀស្ឋជ័យខ្ញាល់លោលោត កូនខ្លាចផ្សិតស្តេចក្រោធ ក្រោកចុះចេញពីបិតា ស្តេចខំបរពលបក្រំង ស្តាប់អស់ទាំងអង្គសេនា ពលពលច្រើនត្រៀបត្រា កូនបានឃាត់ស្តេចពុំស្តាប់ ។ ឥឡូវស្តេចមរណា កើយកេសាជួលដេកផ្ងាប់ ព្រះធរណីពុំគាប់ ពុំគួរកើយនៃក្សត្រា ។ ហេតុកម្មពៀរពីព្រេង មកបង្វែងព្រះពជា ឲ្យក្ស័យនៃជន្មា មកអសារជោយផែនដី ។ នាងសែនសោយសោកសព្ទ ស្ទើរសន្ទប់ជីវិតក្ស័យ ស្រេចទើបនាងស្រីថ្ងៃ បន្ធូរសោកនាងជាយា ។ ក្រាបទូលព្រះពោធិ- សត្វអំពីពលបិតា សូមស្តេចទ្រង់មេត្តា ខ្ញុំបង់លើកសពឡើងថ្វាត់ ។ ព្រះពោធិវង្កូល ជាអម្បូរពង្សពុទ្ធរ័ត្ន ស្តាប់នាងនាថសាសត្វ ទើបបន្ទូលត្រាស់ទៅថា ។ អាមាត្យបូរឆាប់វៃរត់ឃ្មាតខ្ទីប្រាប់សេនា ឲ្យជុំមកមីម្មា ធ្វើមេរុមាសឲ្យឆាប់ៗ ។ អា-មាត្យស្តាប់បន្ទូល ក្សត្រឥស្សូរលាប្រញាប់ ថ្វែងដូចព្រះបង្គាប់ ប្រាប់អស់អង្គមុខមន្ត្រី ។ អស់អ្នកបួលឲ្យឆាប់ រៀបប្រជាប់ទៅវៃៗ ធ្វើមេរុមាសប្រពៃ ជម្កល់សពព្រះបិតា ។ អស់មុខមន្ត្រីផង ស្តាប់រួសរាន់រៀបមិម្មា ពលពាលពាសណែនណា ធ្វើព្រះមេរុមាសបញ្ចង្គ

បទកាកគតិ

ស្តែងស្តេចប្រញាប់ ឲ្យរៀបប្រដាប់ មេរុមាសផ្ចិតផ្ចង់ សាលា
ស្រឡៃ រេចត្រែជាងក្នុង រជាររង្ស រសគូរទូរថ្នាក់ ៗ ប្រដាប់
ប្រដា ប្រដូចសួគ៌ា គាប់គួរដោយថ្នាក់ ដោយថ្នាំងរនម៉ា មាលា
ថ្វាយថ្នាក់ កន្ទង់រួតរក់ រាយរៀបពិតាន ៗ ពាមវែសនត្រ័ន
ឆ័ត្ររួតច្រើនជាន់ រៀបរៀងរល់ហាន ធុះថ្លាស់ពណ្ណរាយ ឆើតឆាយមែន
មាន ពាសទាំងពិតាន ហាំងបំទសោភា ៗ រៀបស្រេចហើយនៃ ពោធិ
សត្វថ្ងៃ នូវនាងជាយា ស្តេចឲ្យលើកសព ព្រះវរបិតា ដម្កល់ដាក់
នា មេរុមាសប្រពៃ ៗ ធ្វើបុណ្យស្រេចបាន ពោធិសត្វសាន្ត
នូវនាងស្រីថ្ងៃ បូជាព្រះសព គ្រាន់គ្រប់ហើយនៃ រើសធាតុក្សត្រថ្ងៃ
ដាក់កោដ្ឋរចនា ៗ ស្តេចបញ្ចុះធាតុ រួបស្រេចនាងនាថ នូវមហាក្ស-
ត្រា ក្រេមក្សាន្តឥតទុក្ខ សាន្តសុខក័យា អស់សំស្នេហា មូលមកជុំ
ជិត ៗ បម្រើមហាក្សត្រ ក្រុញក្រាបប្រតិបត្តិ ព្រះវរមាសមិត្ត ឥ
សូរសេរសី ច្រើនក្រៃពេកពិត អន័ត្យពំនិត ហាក់សួគ៌ាល័យ ៗ
អស់អគ្គសេនា ពលពាលអសុរ ចូលមកក្រាស់ក្រៃ អភិសេកក្សត្រា
ជាយាល្មមលៃ គ្រប់គ្រងបូរី ចូលរាំងរដ្ឋា ៗ ក្រេមក្សាន្តអស់រាស្ត្រ
យក្សយសដេរដាស ចូលថ្វាយវន្ទា ឥតទុក្ខឥតភ័យ ក្សត្រថ្ងៃមេត្តា
ប្រាសាទរាជា នូវនាងមហេសី ៗ សោយរាជ្យយូរលង់ ទៀងទើប
ព្រះអគ្គ និកដល់ជនី ជនកនាយនៃ ក្សត្រថ្ងៃទាំងទ្វី និកដល់បុរី

ពុំដាច់ឡើយណា ៗ ដៀតអញទូលលា មកតាមជាយា ទេពីនោះ

ណា បន្ទូលផ្ដែផ្ដាំ សាំញាំអស់អាថ៌ ឲ្យអញយាត្រា វិលធាប់កុំ

លង់ ៗ ឥឡូវយូរហើយ សមក្សត្រត្រាណត្រើយ តាំងពីព្រះអង្គ

ទន្ទឹងអញនៃ ក្សត្រថ្ងៃពីរពង្ស មានទុក្ខនៅក្នុង ព្រះទ័យសោកា ៗ

គិតស្រេចព្រះអង្គ ព្រះសុវណ្ណហង្ស បន្ទូលត្រាស់ថា ហៃនាងប្អូនស្រី

ប្រឹមប្រើយសោកា បងនឹងលាគលា ប្អូនមាសទន្ទឹង ៗ នឹងទៅនគរ

ព្រួយពុំសាទរ សមនៅស្រុកបង បិតាមាតា ជរាហើយហោង សម

ស្ដេចតែងរង់ ទុក្ខទន្ទឹងក្ដាត់ ៗ បូរនាងប្អូនស្រី គ្រប់គ្រងបុរី ប្រជា

រាស្ត្ររដ្ឋ បងលាប្អូនទៅ លំនៅល្អក្ដាត់ ស្រេចវិលវិញថ្វាត់ ថ្កានប្អូន

ពុំឆា ៗ នាងកេតសុរិយង្គ ស្ដាប់ហើយនាងទ្រង់ អួលអន់ឱក នាង

ក្រាបសិរសី ទួញដិតបាទា បង្គំទូលថា បពិត្រចមទៅ ៗ បើ

ស្ដេចលីលា ហោះបង់នគរ ទុកខ្ញុំឲ្យនៅ សមទល់ទុក្ខធ្ងន់ ពេកពន់

ក្រៃក្រៅ បពិត្រព្រះទៅ យកខ្ញុំទៅផង ៗ ខ្ញុំឥតមេបា ពិក័ក្ដិរក្សា

ហើយមានព្រះបង ជាម្ចាស់សិរសី សព្វថ្ងៃនេះហោង ជីវិតខ្ញុំប៉ង

ស្លាប់ក្រោមបាទា ៗ សោយរាជ្យសម្បត្តិ ប្រជារាស្ត្ររដ្ឋ ស្ដេចពុំមេត្តា

ឲ្យកម្ពុលយក្ស ពិក័ក្ដិរក្សា គ្រប់គ្រងភារា តាំងព្រះមហាក្សត្រ ៗ

គាត់មានគុណក្រៃ កាលស្ដេចក្សណក្ស័យ គាត់ជូនខ្ញុំថ្វាត់ ទៅដល់

ព្រះអង្គ ពូជពង្សព្រុទ្ធរ័ត្ន សូមទានមហាក្សត្រ ឲ្យគាត់គ្រប់គ្រង ៗ

ព្រះសុវណ្ណហង្ស ស្ដាប់នាងវរវង្ស បន្ទូលសាសង បើមាសពុំឆា

នាងទៅទីឯបង គិតខ្លោះគាប់ហោង បងតាមប្អូនស្រី ។ ចូរនាង
ហៅរក កម្ពលយក្សមក ឲ្យដល់ឆាប់ខ្ញី ឲ្យគាត់ស្ទាលស្ទង គ្រប់
គ្រងបុរី ហើយយើងឃ្លាតខ្ញី លាទៅនគរ ។ នាងឮស្វាមី ព្រម
យកក្សត្រថ្វៃ ទៅផងក្រេកអរ នាងនាថចៅពៅ ហៅសៅជ័យមក បង
ទៅគាបអរ . បន្ទូលយក្សា ។ ហៅទានឥសូរ សេនាឲ្យចូល មក
ឲ្យឆាប់ព៉ី សៅជ័យបង្គំ ប្រណម្យលុតលា រូតរត់មិម្មា ស្រែក
ហៅថាហៃ ។ ទានឥសូរ ជាក់ជាសេនា ចូរអ្នកឆាប់វៃ ព្រះ
បន្ទូលហៅ ឲ្យទៅឆាប់ខ្ញី ទើបទានអសុរី រូតរត់មិម្មា ។ ដល់
ស្រេចក្សត្រី បើកព្រះសុវណ្ណី បន្ទូលទៅថា ហៃទានឥសូរយក្ស អង្គ
អគ្គសេនា ព្រះស្ដេចលីលា ហោះទៅកម្ពល ។ នាងបង្ហាញថា
ទិសទីយក្សា នៅព្រៃមណ្ឌល គុហាឋានបិត នៃបទិតជិតដល់ សា-
លាទិមិល ក្រែកសុទ្ធម្ពី ។ បើឃើញជាក់ស្ប័ទ ព្រះស្ដេចរូសពាន់
ប្រាប់ថាក្សត្រា ឲ្យអញ្ជើញទៅ ឥឡូវនេះណា ឲ្យគ្រងភារា មនុស្ស
ទាំងបុរី ។

បទពំនោល

ទានសូរស្ដាប់ហើយឆាប់វៃ លាស្រេចឃ្លាតខ្ញី ហៀរហោះដម្រង់
ទិសា ។ ដែលនាងក្សត្រីកញ្ញា បង្ហាញនោះណា ស្រេចដល់សា-
លាពុំខ្វល់ ។ ទានសូរបរចូលទៅដល់ ទូលស្ដេចកម្ពល បពិត្រព្រះ
បាទរាជា ។ ទាំងពីរព្រះអង្គនៅនា មនុស្សទាំងភារា ប្រើឲ្យអញ្ជើញ

ទៅថ្វាត់ ៗ ដ្បិតស្ដេចនឹងឲ្យមហាក្សត្រ សោយរាជសម្បត្តិ សម្បូរ នគរគ្រាមា ៗ កម្ពលស្ដាប់ហើយម្មា ហៅនន្ទកេជា អនុជមក ប្រាប់ពត៌មាន ៗ ថាពីព្រះមហាក្សត្រក្បាន្ត ត្រាស់ឲ្យហោះឈ្យាន ទៅគ្រង់នគរគ្រាមា ៗ មនុស្សទាំងបូរីរដ្ឋ ភ្ញាះហើយបូរបា នៅ ចាំសាលារាជហាន ៗ បងនឹងលីលាហោះឈ្យាន ឥឡូវពុំខាន ជា មួយនឹងទានសេនា ៗ ផ្ដាំស្រេចស្ដេចចាប់ពេជ្រថ្វា ហោះហួសវេ- ហាស៍ ស្រេចដល់មនុស្សទាំងនគរ ៗ កម្ពលចូលដល់លើកករ អញ្ជ- លីថ្វាយវរ បង្គំប្រណម្យរាជា ៗ ស្ដេចយល់កម្ពលអសុរា ទើប នាងជាយា សាកសួរទទួលអស់ក្ដី ៗ ស្រេចទើបស្ដេចថាក្សត្រី មានតម្រាស់វៃ សំណេះសំណាលបរតា ៗ ហៅយក្សកម្ពលបូរបា សេពសោយរាជា ជាស្ដេចគ្រងរាជបូរី ៗ សេនាយោធាមន្ត្រី ពល ពលសេនីយ បូរីបូរណគ្រាមា ៗ ដ្បិតស្ដេចភាត់ត្រេចយាត្រា ដល់ឋាននាយេណា អញ្ជើញទៅទីព្រះចក្រី ៗ បាចាំថៃទាំងបូរី សេនាមន្ត្រី ទម្រាំយើងវិលយាត្រា ៗ កម្ពលយក្សយល់អសុរា ស្ដាប់ហើយវន្ទា ទទួលតាមរាជសុវណ្ណី ៗ ស្រេចហើយព្រះបាទចក្រី នូវនាងក្សត្រី អភិសេកកម្ពលយក្ស ៗ ឲ្យគ្រងរដ្ឋរាជសេមា ស្រាប់ ស្រេចហើយណា ក្សត្រានាំរាជទេវី ៗ ចូលផ្ទុំសុខសិរិវឌ្ឍី លុះព្រឹក ឡើងខ្វី សម្ដេចព្រះបាទរាជា ៗ នូវនាងរដ្ឋរាជជាយា ស្រង់ព្រះ គង្គា ជម្រះព្រះអង្គទាំងទ្វេ ៗ ទ្រង់សុគន្ធមាលេ សម្រេចទាំងទ្វេ

ហើយទ្រង់គ្រឿងទាំងពីរពង្ស ៗ នាងកេតសុរិយគ្គុកាស កែម
កែវចុះផ្លាស់ ស្តេចទ្រង់មកុដពេជ្ជមុគ្គា ៗ រស្មីថ្វាយង់វង់ថ្វា ក្ដីផ្គក
មហិមា គ្រប់គ្រងក្រោនក្រាត ៗ ស្តេចសៀតព្រះខ័នជ័យស្អាត
ព្រះហស្តក្ងនាថ ទ្រង់ឆកោទណ្ឌសរថ្វា ៗ ស្រេចស្តេចយានយាស
យាត្រា នាំពលជាយា ឡើងគង់សិទ្ធតាមនោម័យ ៗ

## បទកាកគតិ

ស្តេចគង់អស្សពាហ៍ នាមឈ្មោះហៅមហា ភាមាជៀស្គជ័យ
ពូជពង្សវង្សា អស្សពាហ៍ប្រពៃ បង់គ្រឿងមាសមៃ លាយឡំសូរ្យ-
កាន្ត ៗ ប៉ែកឈ្នាន់ឃ្មុំមួយ បង្ហៀររឹតអុក គ្រប់បំណាន ក្រឡា
បត្រគ្គ បញ្ចូន់លំអាន រំលេចសូរ្យកាន្ត ពេជ្រព័ន្ធរក្ខា ៗ ព្រះ
ពោធិសត្វ នៅខាងស្រីរ័ត្ន ស្តេចគង់អស្សពាហ៍ ទាំងពីរព្រះអគ្គ
ពូជពង្សពុទ្ធា ហៀរហោះវេហាស៍ ត្រៃសតយល់ឆ្ងាយ ៗ ក្តីព្រោង
ព្រាយព្រាត ទាំងគូរនាថ ផ្លាស់ចុះពីទាយ ដូចព្រះសូរ្យសែង
ក្តីបែងឡើងសាយ រស្មីពណ្ណរាយ ពាសពេញវេហាស៍ ៗ សេះ
ហោះខៀវខ្វាល់ លឿនលន់ពព្រាល់ លើអាកាសា ឆ្ងាយណាស់
ពេកក្រៃ ល្ងាចថ្ងៃសុរិយា ហេតុកម្មធីតា ឯងឲ្យប្រាសព្រាត់ ៗ
កាលនោះកញ្ញត្រី ក្ដាំងក្មេងស្មារតី ហាក់ទឹងបំបាត់ ជីវិតសូន្យសោះ
ទៀនទូលមហាក្សត្រ បពិត្រប្រកព័ត្ត ឥស្សរសិរសា ៗ ខ្ញុំនេះនៃ
ក្មេងក្ដាំងស្មារតី ហាក់ទឹងមរណា សូមតានស្តេចឈប់ ក្រោម

ទំហិង្ស បណ្តុបសនាក ក្រែងខ្ញុំក្សិណក្ស័យ ។ បន្ទូលម្ល៉ោះស្រេច ក្សិណនោះសម្តេច ក្សត្រីស្រីថ្ងៃ សន្ធប់បំបាត់ សូន្យស្ងាត់ហើយនៃ ព្រះបាទជៀស្ឋជ័យ ព្រួយព្រះបិត្តា ។ ស្តេចភ័យពេកសល់ ព្រឺព្រួយអស់កល់ ចាំទុជាយា ហេតុម្តេចចេះនៃ ក្សិណក្ស័យជន្មា លើអាកាសា សន្ធប់លុះលង់ ។ ព្រះហស្តប្រាំ ទុបជិតទិព ហើយក្សត្រវរង្ស ទតយល់សាលា មួយណាបញ្ជូគ បន្ទូលត្បោះត្រង់ ហៃបាមនោម័យ ។ បុះធាប់រួសា៉ បូលបតសាលា ព្រះឥសីថ្ងៃ ជ្សិតនាងសន្ធប់ សូន្យសត្វពេកក្រៃ បើភ្ញាក់ស្មារតី សឹមយើងយាត្រាៗ សិន្ធពមនោម័យ ស្តាប់ហើយស្រដី ទូលព្រះពជា បពិត្រព្រះបាទ នរនាថថ្ងៃថ្វា ពុំមែនសាលា ព្រះឥសីថ្ងៃ ។ សមសាលាយក្ស អសុរសំណាក់ ចិតនៅនេះនៃ កុំអាលព្រះបាទ នរនាថជៀស្ឋជ័យ ចរចុះខ្លាចភ័យ ដួចដល់អាត្មា ។ ហេតុកម្មទេវី ពុំឲ្យបក្រី យកពាក្យអសុរពោហ៍ នឹងឲ្យទ្រាត់ប្រាស់ និពសឃ្មាតឃ្មា ធ្លាក់ក្នុងគង្គា ស្មើរក្ស័យជីពជន្ម ។ ព្រះពោធិសត្វ ទាញមនោម័យឃាត់ ចរចុះធាប់លន់ ដួចដល់សាលា ក្សត្រាគយគន់ មើលមុខស្រីតន់ ពុំភ្ញាក់អាត្មា ។ ស្តេចថ្នមមហេសី បីដាក់ដល់ទី មណ្ឌលសាលា ស-ន្ធប់សូន្យសុង យូរលុងក្តាត់ណា ព្រះហស្តក្សត្រា បង្គំអធិដ្ឋាន ។ បពិត្រទេវតា អ្នកចិតនៅនា ព្រៃព្រឹក្សវិមាន រុក្ខាទេវា ទេពតាសត្វបាន ជួយនាងកល្យាណ ជាតិជាមហេសី ។ ក្សារភ្ញាក់ឡើង

ថ្វាត់ ដូចពាក្យសារសព្ទ រសៀបជីវី ឲ្យ[illegible] បរិពេ
សោកី មែនមានស្មារតី ដូចដើមវិញណា ។ ស្រាក់ស្រួលចាបែង
ចរចាថ្វាថ្វែង ទូលព្រះពជា បពិត្រខ្លួនខ្ញុំ ហេតុកម្មវេរា អ្វីដល់
កាយា ប្រាកដនេះមួង ។ សាបសូន្យអស់អង្គ ស្មើក្ស័យបាត់បង់
ជីវិតទៅហោង ស្ដេចថាឪស្ងួន ខ្ញុំមខ្លួនទង់វង់ ពុំដែលហោះផ្សង
ដើរដោយវេហាស៍ ។ ហោះខ្ពស់ត្រូវខ្យល់ ប៉ុកសៀតញាប់ញ័រ ពន្ទឹក
មហិមា ឥឡូវយើងខាន សម្រាន្តនៅនា តិចសីមលីលា ចរចេញ
ទៅថ្វាត់ ។ គិតព្រមគ្នាស្រេច កញ្ញាណនោះសម្ដេច បន្ទូលសាសព្ទ
ហៃបងអសុរពាហ៍ ចូរបាប្រយ័ត្ន ឲ្យនាងស្រីរត្ន លំហើយហឫទ័យៗ
ព្រះពោធិវង្ស ជុំទាំងពីរពង្ស ទិត្យនៅនោះនៃ ព្រះពាយផាយផាត់
សប្បាយពេកក្រៃ ព្រះបាទជៀស្ដជ័យ នូវនាងធីតា ។ ផុលក់អស់កល
សិទ្ធពនិមិល ជីងដើមក្សត្រា ផុលក់នៅឋាន វិមានអសុរា
សិទ្ធពម្ចីមា ប្រុងប្រាណរំពៃ ។ ចាំនៅក្រៅឋាន ប្រយ័ត្ន
ក្រែងមាន សត្រូវពោសពៃរ៍ កាលនោះអសុរា យក្សាបក្រែង
សំណាក់នៅនៃ ព្រៃព្រឹក្សសមសាន្ត ។ នាមឈ្មោះវិរុល- មេឃមីរ
អសុរ ក្រែកសុចិត្រា ស្ថិតនៅព្រឹទ្ធ ដែលមានសាលា វិរុលហោះហា
ហើរបរិគោត្តា ។ ជួបគ្រប់ប្រាំពីរ ថ្ងៃទើបវិលវិល មកមើលសាលា
វិរុលហៀរហោះ ផ្តុកផ្តោះវេហាស៍ ពលហើរម្ចីមា រមិលយង់
យល់ ។ ព្រះបាទក្សត្រា ទឹងនាងធីតា ផុលក់សុខសល់ យក្ស

ក្រោធា មនុស្សក៏ហ៊ានផល់ ដេកនៅមណ្ឌល ពីនាក់ជាម្តង ។ សព្វថ្ងៃអញបរ ចេញចាកពីប- រមោជនេះហោង វិលវិញសម្រាន្ត ពុំមានត្គាំត្គង គោះយក្សយង់យួង ក្រុឌនាគរាជា ។ ពុំហ៊ានវិលង បៀសរាំងច្រើនផង ខ្វបខ្វាយបេស្តា អស់មនុស្សនេះហ៊ាន លលាន មហិមា ពុំខ្វាបមរណា ផល់ប៉ុនកេសី ។ គិតស្រែបសូន្យសព្វ ទន្ទេញទន្ទុប ទន្ទាបផល់ដី ផ្ទុមផ្ទាមផ្ទិងផ្ទុង យល់យង់ទេវី ល្អល្អះ លែងស្រី ទិព្វទេពសួគ៌ា ។ យក្សអរឯងអរ លាភអ៊ីបវរ ថ្ងៃនេះ ឯងណា វិលមកមានលាភ សុភាពថ្ងៃថ្លា បួលត្រូវវេលា មាន ស្រីស្ងួស្តិ៍សម ។ យកជាករិយា ឥឡូវនេះណា គួរអញសណ្តុំ ឲ្យលក់និទ្រា នៅនាបន្ទុំ ស្រេបហើយអញស- ម្លាប់ប្តីឲ្យក្ស័យ ។ គិតស្រែបធ្លាក់ធ្លៀង ដើបដើតទតទៀង យល់សេះមនោម័យ ដេក ខាងសាលា នេត្រារំពៃ ចាំនាងនៅនៃ ទៀងទើបយក្សា ។ លូនលបចេញក្រៅ រកថ្នាំសង្កូវ បានហើយម្ទីម្ទា សូត្រសែបអាគម សណ្តំក្សត្រា ទូវនាងជាយា សេះស្ងួស្តិ៍មនោម័យ ។ ហេតុសិល្ប៍ សាស្ត្រយក្ស រឹងឫទ្ធិស័ក្តិ ត្រូវមហាក្សត្រិថ្ងៃ ទូវនាងធីតា ជាយា ល្មៃល្ម ផ្ទុលក់ពេកក្រៃ ពុំភ្ញាក់ភ្ញាក់ប្រាណ ។ តែរាជអស្សតរ មន្តលបវរ ចាប់ឃុំពុំបាន ត្រូវសិល្បសាស្ត្រយក្ស ភ្ញាក់ភ្ញាក់លឹកលាន ប្រែប្រួលប្រឹងប្រាណ ប្រាប់ព្រះពោធិ ។

ចប់ខ្សែ ២ សូមអានខ្សែ ៣ តទៅទៀត